# អ្នកនាំសារ
## The Messenger

41

ខែធ្នូ ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ



# ទិវាខួប ៤៥០ឆ្នាំ នៃ ព្រះសហគមន៍កាតូលិក !



មន្ទីរពេទ្យភ្នែកតាកែវជួយអ្នកជំងឺគ្រប់វណ្ណៈ

ទំព័រ ៦



ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់

ទំព័រ ១១

សូមផ្ញើជីវិតលើព្រះជាម្ចាស់ហើយ!

ទំព័រ ១២

## សំនួរក្មេងៗ

## ស្វែងយល់ពាក្យក្នុងគម្ពីរ !



Photo: DR

ប្អូនៗ ធ្លាប់បានឮពាក្យខ្លះៗក្នុងគម្ពីរដូចជា : បុត្រមនុស្ស យញ្ញបូជា និង វិសុទ្ធ។ តើពាក្យទាំងនេះមានន័យដូចម្ដេចខ្លះ ?

**បុត្រមនុស្ស :** មានន័យថា “មនុស្សសាមញ្ញធម្មតា”។ គម្ពីរព្យាការីអេសេគីអែល ប្រើពាក្យនេះដើម្បីសម្ដែងឱ្យដឹងថា ព្រះជាម្ចាស់ និងមនុស្សយើងខុសប្លែកគ្នាឆ្ងាយណាស់។ គម្ពីរព្យាការីអេសេគីអែល (៧,១៣) ប្រើពាក្យនេះ សំដៅលើមនុស្សដែលមកពីស្ថានបរមសុខ ទទួលអំណាចលើប្រជាជនក្នុងពិភពលោកទាំងមូល។ ចំពោះព្រះយេស៊ូ ប្រើពាក្យនេះ សំដៅលើព្រះអង្គផ្ទាល់តែម្ដង ដើម្បីឱ្យដឹងថា ព្រះអង្គជាមនុស្សធម្មតា ដែលទន់ខ្សោយផង និងជាព្រះគ្រីស្ត ដែលយាងមកពីស្ថានបរមសុខដើម្បីសង្គ្រោះមនុស្សលោកផង (ម៉ាថាយ ៩,៦-២៦,៦៤)។

**យញ្ញបូជា :** ជាពិធីមួយ ដែលជនជាតិអ៊ីស្រាអែលយកសត្វមកសម្លាប់បូជាថ្វាយព្រះជាម្ចាស់ដើម្បីទូលសូមព្រះអង្គលើកលែងទោសឱ្យរួចពីបាប ឬដើម្បីអរព្រះគុណព្រះអង្គ។ យញ្ញបូជាមួយចំនួន ជាពិសេសយញ្ញបូជាមេត្រីភាព គេដុតសាច់ មួយផ្នែកគេថ្វាយនៅលើអាសនៈ មួយផ្នែកទៀតគេជូនបូជាចារ្យ ហើយមួយផ្នែកធំដែលនៅសល់ ទុកបរិភោគខ្លួនឯង។ ចំពោះយញ្ញបូជាមួយប្រភេទទៀត គឺដង្វាយដុតទាំងមូល គេដុតដង្វាយទាំងមូលនៅលើអាសនៈ។

**វិសុទ្ធ :** គឺជានិស្ស័យ ឬគុណសម្បត្តិពិសេសរបស់ព្រះជាម្ចាស់ខុសប្លែកពីសត្វលោកដែលព្រះអង្គបង្កើតមក។ មនុស្សលោក ឬអ្វីៗទាំងអស់ ដែលនៅជាប់នឹងព្រះអង្គ ព្រះអង្គប្រោសប្រទានឱ្យបានវិសុទ្ធដែរ។ ក្រុមគ្រីស្តបរិស័ទខ្លះប្រើពាក្យ “បរិសុទ្ធ” ខ្លះទៀតប្រើពាក្យ “សន្តបរិសុទ្ធ”។

អ្នកនាំសារ

## អធិប្បាយព្រះបន្ទូល

### ថ្ងៃអាទិត្យ ទី១៧ ធ្នូ ២០០៦ ក្នុងរដូវរង់ចាំព្រះគ្រីស្តយាងមក

### “ត្រូវចេះចែករំលែកចំពោះគ្នាទៅវិញទៅមក”

(លូកា ៣,១០-១៨)

លោកយ៉ូហានធ្វើពិធីជ្រមុជទឹកដើម្បីរៀបចំប្រជាជនមួយទុកសម្រាប់ព្រះគ្រីស្ត។ នាសម័យនោះ គេរង់ចាំព្រះគ្រីស្តយ៉ាងខ្លាំង គឺរង់ចាំស្ដេចមួយអង្គដែលយាងមកប្រទានសេចក្ដីសុខសាន្តគ្រប់យ៉ាង តាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ កាលពីដើម។ លោកយ៉ូហានស្មានថា កាលដែលព្រះគ្រីស្តយាងមកនោះ លោកនឹងបំផ្លាញអ្នកបាប គឺថាលោកប្រើឫទ្ធានុភាពនៃព្រះវិញ្ញាណមកបំផ្លាញអ្នកបាប ដូចជា យកសំដីស្រូវទៅដុតចោលក្នុងភ្លើងដូច្នោះដែរ។ ពេលក្រោយមក កាលលោកឃើញព្រះយេស៊ូមកទាក់ទង ជាមួយអ្នកបាប លោកនឹកឆ្ងល់ម៉្យាងថា លោកយេស៊ូនេះគឺដូចជាព្រះគ្រីស្ត តែលោកមានចិត្តមេត្តាករុណាចំពោះអ្នកបាបដែលខុសនឹងសេចក្ដីដែលលោករង់ចាំ។

ទោះបីជាលោកយ៉ូហានយល់ច្រឡំអំពីលក្ខណៈព្រះគ្រីស្តយ៉ាងណាក៏ដោយ គឺលោកប្រៀនប្រដៅយើងសព្វថ្ងៃ ដូចលោកប្រៀនប្រដៅអ្នកស្រុកនៅសម័យលោកដែរ គឺថាប្រសិនបើយើងចង់ទទួលព្រះគ្រីស្ត យើងមិនបាច់ដូរអាជីវកម្មទេ មិនបាច់ចូលបួសទេ ក៏មិនត្រូវធ្វើការអស្ចារ្យដែរ គឺត្រូវតែគោរពអ្នកដទៃ ត្រូវប្រព្រឹត្តតាមយុត្តិធម៌ មានចិត្តមេត្តាករុណាដល់អ្នកក្រីក្រ និងកុំប្រើហិង្សា-ល-។ ប្រសិនបើយើង



ធ្វើការក្នុងអង្គការមនុស្សធម៌ សូមកុំលួចម្ចាស់អំណោយ និងកុំកេងបន្លំ -ល-។ ត្រង់នោះ លោកយ៉ូហានប្រៀនប្រដៅយើងដូចព្រះយេស៊ូដែរ។ ជំនឿជំរុញយើងឱ្យប្រែរបៀបរស់នៅ ដោយយើងជឿយ៉ាងជាក់ច្បាស់ថា មនុស្សគ្រប់ៗរូប គឺសុទ្ធតែជាតំណាងរបស់ព្រះជាម្ចាស់ ដែលប្រសូតជាមនុស្ស។ អ្នកចង់គោរពបំរើព្រះជាម្ចាស់ ត្រូវតែគោរពមនុស្សគ្នាឯងវិញ។ នេះជាដំណឹងល្អសម្រាប់យើងនៅថ្ងៃអាទិត្យនេះ។

### ថ្ងៃអាទិត្យ ទី២៤ ធ្នូ ២០០៦ ក្នុងរដូវរង់ចាំព្រះគ្រីស្តយាងមក

### “នាងពិតជាមានសុភមង្គល ព្រោះនាងបានជឿព្រះបន្ទូល”

(លូកា ១,៣៩-៤៥)

លោកលូកាតែងរៀងព្រេងរៀបរាប់អំពីកំណើតព្រះយេស៊ូ តាមរបៀបសម្ព័ន្ធមេត្រីចាស់។ លោកចែងដូច្នេះដោយមានបំណងពន្យល់អំពីឋានៈរបស់ព្រះយេស៊ូជាព្រះគ្រីស្ត និងជាព្រះអម្ចាស់តាមជំនឿរបស់ក្រុមសាវ័ក ដែលចាប់ផ្ដើមជឿបែបនេះ ក្រោយពេលលោកយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង។

នៅក្នុងអត្ថបទនេះ សូមចាប់អារម្មណ៍អំពីកូននាងអេលីសាបិត បម្រាស់ក្នុងពោះម្ដាយ។ កូននោះរាំក្នុងពោះ ដូចព្រះបាទដាវីឌ រាំនៅចំពោះហិបនៃសម្ព័ន្ធមេត្រី កាលស្ដេចទ្រង់នាំហិបនោះទៅតម្កល់នៅក្រុងយេរូសាឡឹម (២សម ៦,២-១៦)។ បានសេចក្ដីថា នាងម៉ារីគឺប្រៀបដូចហិបនៃសម្ព័ន្ធមេត្រីផ្ទុកដោយព្រះអង្គម្ចាស់ គឺព្រះយេស៊ូ ជាព្រះអម្ចាស់នោះមែន។

ក្នុងគម្ពីរដំណឹងល្អ មិនមានចែងយ៉ាងវែងពីនាងម៉ារីនោះទេ ពីព្រោះអ្នកនិពន្ធមានបំណងពន្យល់ថា ព្រះ



យេស៊ូជាព្រះសង្គ្រោះ តែមួយព្រះអង្គគត់ គឺគ្មានព្រះសង្គ្រោះណាផ្សេងទៀតទេ។ រីឯនាងម៉ារីគឺជាគ្រីស្តបរិស័ទគំរូព្រោះនាងជឿមុនគេ។ ពេលយើងជាគ្រីស្តបរិស័ទកាតូលិក គោរពនាងម៉ារី យើងរួមជាមួយនាង ជាគ្រីស្តបរិស័ទមុនគេ នឹករលឹកនូវការអស្ចារ្យទាំងប៉ុន្មានដែលព្រះជាម្ចាស់បានប្រព្រឹត្តដើម្បីឱ្យយើងទទួលជីវិតថ្មីរួមរស់ជាមួយព្រះអង្គ។



### ថ្ងៃទី២៥ ធ្នូ ២០០៦ បុណ្យរំឭកព្រះយេស៊ូប្រសូត

### “ព្រះជាម្ចាស់ប្រសូតជាមនុស្ស ដើម្បីឱ្យមនុស្សយើងទៅជាព្រះជាម្ចាស់”

(លូកា ២១-១៤)

“ព្រះជាម្ចាស់ប្រសូតជាមនុស្ស ដើម្បីឱ្យមនុស្សយើងទៅជាព្រះជាម្ចាស់”។ លោកអ៊ីរេណេ ជាអភិបាលក្រុងលីយ៉ុង កាលពីដើម (នៅគ.ស ១៧២) បានចែងសេចក្ដីនេះ ដើម្បីពន្យល់អត្ថន័យ អំពីកំណើតព្រះយេស៊ូ។ ក្នុងការរំឭកបុណ្យព្រះយេស៊ូប្រសូតនោះ យើងនាំគ្នាលើកតម្កើងតម្លៃដ៏ថ្លៃថ្នូររបស់មនុស្ស ពីព្រោះមនុស្សគ្រប់រូប ជាតំណាងរបស់ព្រះជាម្ចាស់ក្នុងលោកនេះ។ បុណ្យព្រះយេស៊ូប្រសូតពិតជាបុណ្យគោរពសិទ្ធិមនុស្ស។ ដោយព្រះជាម្ចាស់ប្រសូតជាមនុស្សដូចយើង ជីវិតយើងមានតម្លៃ!។

លោកលូកានិពន្ធរឿងព្រេងអំពីកំណើតនៃព្រះយេស៊ូដោយមានបំណងពន្យល់អំពីព្រះរាជកិច្ចរបស់ព្រះយេស៊ូ។ លោកចែងអំពីនិមិត្តរូបជាច្រើន មានដូចជាទេវទូតច្រៀងចម្រៀង ចុះឡើងពីស្ថានបរមសុខមកលើផែនដី គឺលោកចង់ពន្យល់ថា ព្រះយេស៊ូកើតមកជាមនុស្ស ដែលធ្វើឱ្យព្រះជាម្ចាស់ និងមនុស្សលោកមានទំនាក់ទំនងជាមួយគ្នា។ ព្រះយេស៊ូដូចជាបើកទ្វារស្ថានបរមសុខឱ្យយើង។ ព្រះយេស៊ូយាង



មកសម្ដែងនូវព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះមនុស្សលោកយើងរាល់គ្នា ហើយព្រះអង្គប្រទានសេចក្ដីសុខសាន្តដ៏ពិតប្រាកដ ពីព្រោះមនុស្សស្គាល់ទិសដៅនៃជីវិតរបស់ខ្លួន ដោយគេអាចទាក់ទងជាមួយព្រះបិតានៅក្នុងឋានៈជាបុត្រធីតា ដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ សូមនឹកសញ្ជឹងពីរឿងព្រេងនេះដែលមានអត្ថន័យយ៉ាងជ្រៅ និងសំខាន់សម្រាប់យើងនាបច្ចុប្បន្នកាលនេះ។

### ថ្ងៃអាទិត្យ ទី៣១ ធ្នូ ២០០៦ បុណ្យព្រះរាជវង្ស

### “កូនត្រូវនៅក្នុងដំណាក់ព្រះបិតារបស់កូន”

(លូកា ២,៤១-៥២)

លោកលូកាចែងរឿងព្រេងស្ដីអំពីព្រះយេស៊ូកុមារ ដើម្បីរិះគិតអំពីឋានៈរបស់កុមារយេស៊ូនោះ។ កុមារយេស៊ូដូចក្មេងៗឯទៀតៗ តែព្រះកុមាររួមរស់ជាមួយព្រះបិតា នឹកដល់ព្រះបិតាគ្រប់ពេលវេលា ដូចនៅពេលក្រោយកាលព្រះអង្គបំពេញព្រះរាជកិច្ច ទ្រង់ផ្ញើជីវិតលើព្រះបិតាដែរ។ ឪពុកម្ដាយរកកុមារយេស៊ូអស់រយៈពេលបីថ្ងៃ ដូចនៅពេលក្រោយក្រុមសាវ័កយកព្រះយេស៊ូដែលត្រូវគេឆ្កាងបីថ្ងៃដូច្នេះដែរ។

បងប្អូនដែលមានកូនមានចៅត្រូវនឹកថា បងប្អូនបង្កើតកូនមែន គឺបងប្អូនបន្តជីវិតពីព្រះជាម្ចាស់ដែលជាប្រភពនៃជីវិតមកកូន។ បងប្អូនជាសហការីនៃព្រះជាម្ចាស់ ដោយបានបង្កើតកូន។ សេចក្ដីនេះអស្ចារ្យណាស់។ ស្នេហាមានតម្លៃដ៏ថ្លៃប្រសើរ ហេតុនេះហើយគ្រប់អរិយធម៌ ការពារសេចក្ដីស្នេហានេះ ដោយបង្កើតនូវវិន័យយ៉ាងតឹងរ៉ឹង។

ប៉ុន្តែបងប្អូនត្រូវនឹកទៀតថា បងប្អូនមិនមែនជាព្រះជាម្ចាស់លើកូនទេ ដូចនាងម៉ារី និងលោកយ៉ូសែប



មិនមែនជាម្ចាស់កុមារយេស៊ូដែរ។ កុមារយេស៊ូជាព្រះបុត្រារបស់ព្រះបិតា។ កូនៗបងប្អូន ក៏ជាបុត្រធីតារបស់ព្រះបិតាដែរ។ ហេតុនេះត្រូវយកចិត្តទុកដាក់អប់រំកូនៗ ឱ្យចម្រើនឡើងលើគ្រប់វិស័យ ឱ្យកូនបានទៅរៀន ឱ្យកូនស្គាល់ព្រះបិតារបស់ខ្លួន និងត្រូវគោរពសិទ្ធិកូន-ល-។ ធ្វើដូច្នេះបងប្អូនពិតជាគោរពព្រះជាម្ចាស់ដែលប្រសូតជាមនុស្ស។

**សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា !**



### “ព្រះបន្ទូលបានយាងមកគង់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ តែប្រជារាស្ត្រនោះពុំបានទទួលស្គាល់ព្រះអង្គឡើយ”



Photo: S. Philong

ខែតុលាកន្លងទៅនេះ យើងបានប្រារព្ធមហាសន្និបាត **Asian Mission Congress** នៅឈៀងម៉ៃ ប្រទេសថៃ ដោយមានចូលរួមពីតំណាងព្រះសហគមន៍ជាង ១ពាន់នាក់ ពី២៨ប្រទេសនៃទ្វីបអាស៊ី។ នោះជាឱកាសពិសេសឱ្យព្រះសហគមន៍រិះគិតពិចារណាពីរបៀបប្រកាសប្រវត្តិព្រះយេស៊ូដល់ប្រជាជនអាស៊ី។ ទ្វីបអាស៊ីជាប្រភពនៃទំនៀមទម្លាប់ប្រពៃណី វប្បធម៌ និងពិសេសជាទីកំណើតរបស់ព្រះសង្គ្រោះ យេស៊ូគ្រីស្ត តាមព្រះបន្ទូលសន្យា។ យើងសោកស្ដាយក្នុងផ្លូវចិត្តជាខ្លាំងក្រោយពីអានអត្ថបទដើមដំបូងក្នុងសៀវភៅយ៉ូហានដែលមានឃ្លាថា : “ព្រះបន្ទូលបានយាងមកគង់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ តែប្រជារាស្ត្រនោះពុំបានទទួលស្គាល់ព្រះអង្គឡើយ”។

ឥឡូវនេះ ដល់ពេលយើងដែលទទួលពន្លឺពីព្រះអង្គ នាំពន្លឺនេះដល់អស់អ្នកនៅជុំវិញយើង។ “...ប្រសិនបើខ្ញុំមិនផ្សាយ ដំណឹងល្អទេ សូមឱ្យខ្ញុំវេទនាចុះ !” (១កូរិនថូ ៩,១៦ខ) នេះពាក្យសំដីលោកប៉ូលដែលអប់រំយើង។ យើងមានកិច្ចការរស់នៅតាមព្រះបន្ទូល និងបន្តបេសកកម្មប្រកាសពីព្រះគ្រិស្ត ដោយអំណរសប្បាយ ជំនឿស្មោះ និងការលះបង់ប្រចាំថ្ងៃចំពោះអ្នកដទៃ។

បងប្អូនជាទីស្រលាញ់! ចំពោះខួប៤៥០ឆ្នាំនៃព្រះសហគមន៍កាតូលិកនៅកម្ពុជាឆ្នាំនេះ ខ្ញុំផ្ទាល់សូមសម្ដែងនូវអំណរសប្បាយយ៉ាងជ្រាលជ្រៅ និងដោយគោរពដ៏ខ្ពង់ខ្ពស់។ បុណ្យព្រះយេស៊ូប្រសូត! ខ្ញុំអធិដ្ឋាន សូមព្រះជាម្ចាស់ប្រទានព្រះពរ បងប្អូនឱ្យមានសេចក្ដីសុខក្នុងចិត្ត និងសុភមង្គលជានិរន្តរ៍។

លោកអគ្គរាជទូតសាវ៉ាទ័រ ពេណ្ណាស៊ីអូ

# “យុវជនបំរើព្រះជាម្ចាស់គ្មានព្រំដែនកំណត់”



Photo: DR

ថ្ងៃ២៨-២៩ តុលា ២០០៦ សហគមន៏គូស្វាមីភរិយាសម្រាប់ព្រះគ្រីស្ត Couples for Christ បានរៀបចំសន្និបាតយុវជនមួយសម្រាប់ប្រទេសដែលស្ថិតនៅអនុតំបន់ទន្លេមេគង្គក្រោមប្រធានបទ : “ការបំរើរបស់យុវជនចំពោះព្រះជាម្ចាស់ដោយគ្មានដែនកំណត់”។ ពិធីនេះបានរៀបចំឡើងនៅសណ្ឋាគារ Imperial Garden Villa and Hotel។ សមាជិកចូលរួមជាយុវជនមកពីប្រទេសហ្វីលីពីន វៀតណាម ឡាវ ថៃ ភូមា ឥណ្ឌូនេស៊ី និងកម្ពុជាដែលសរុបមានប្រមាណជា ៨០នាក់។ អត្ថន័យនៃអង្គសន្និបាតផ្តោតលើព្រះអំណោយទានដ៏ច្រើនលើសលប់ និងគ្មានដែនកំណត់របស់ព្រះជាម្ចាស់ដល់យុវជន ដែលជាបេសកជនក្នុងការប្រកាសដំណឹងល្អទៅដល់មនុស្សគ្រប់ជាតិសាសន៏។ នៅក្នុងពិធីមានការផ្លាស់ប្តូរបទពិសោធន៏ក្នុងការប្រកាសដំណឹងល្អ និងមានការបង្ហាញនូវរបាំប្រពៃណីវប្បធម៌របស់ប្រទេសនីមួយៗផងដែរ។

រ័ត្ន ធីតា

## សិក្ខាសាលាស្តីអំពីអន្តរជំនឿ

កាលពីថ្ងៃទី៨-១១ វិច្ឆិកា ឆ្នាំ២០០៦ មានសិក្ខាសាលា ស្តីអំពីអន្តរជំនឿ រៀបចំឡើងដោយក្រុមគណៈកម្មាការអន្តរជំនឿ។ ពិធីនេះរៀបចំនៅសាលាកសិកម្មខេត្តបាត់ដំបង ដែលមានសមាសភាពចូលរួម មកពីតំណាងសាសនានានា ក្នុងខេត្ត គឺ សាសនាកាតូលិក ប្រូតេស្តង់ អ៊ីស្លាម និងពុទ្ធសាសនា។ សិក្ខាសាលា គឺមានគោលបំណងចង់ឱ្យសិក្ខាកាមចូលរួមទាំងអស់ស្វែងយល់អំពីការប្រតិបត្តិទំនៀមទម្លាប់ប្រពៃណីនៃការថ្វាយបង្គំក្នុងសាសនានីមួយៗ ព្រមទាំងស្វែងយល់ពីភាពយល់ច្រឡំរវាងគ្នាអំពីសាសនាមួយទៅកាន់សាសនាមួយផ្សេងទៀតផងដែរ។

ភី រុណ


# អេម៉ានូអែល

សំឡេងពីព្រះសហគមន៏កាតូលិក !



បាត់ដំបង : FM 91.0 Mhz

ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

ភ្នំពេញ : FM 99.5 Mhz

ម៉ោង ៧:០០-៧:៣០ រាល់ល្ងាចថ្ងៃសៅរ៍។

កំពង់ធំ : FM 107.3 Mhz

ម៉ោង ៥:៣០-៦:០០ រាល់យប់ថ្ងៃសៅរ៍។


## CD ចម្រៀង និងល្ខោន អំពីកំណើតព្រះយេស៊ូ

ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតឆ្នាំ២០០៦នេះ មណ្ឌលផ្សព្វផ្សាយព័ត៌មានព្រះសហគមន៏កាតូលិកមានផលិត CD ចម្រៀង និងល្ខោននិយាយអំពីជីវៈប្រវត្តិរបស់ព្រះយេស៊ូប្រសូត។ ប្រសិនបើបងប្អូនមានចំណាប់អារម្មណ៏នោះ សូមអញ្ជើញចូលរួមជាវដោយទាក់ទងមកកាន់ការិយាល័យយើងខ្ញុំ។ ទូរស័ព្ទ : ០២៣ ២២៤ ១២០ ឬ០១២ ២៤៤ ៧៧៨។

សូមអរគុណ !

## ស្រឡាញ់ព្រះជាម្ចាស់ គឺយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ

កាលពីរាត្រី ថ្ងៃសៅរ៍ ទី០២ ធ្នូ ឆ្នាំ២០០៦ សហគមន៏គូស្វាមីភរិយាសម្រាប់ព្រះគ្រីស្ត Couples For Christ បានរៀបចំពិធីជប់លៀងនិងកម្មវិធីប្រគុំតន្ត្រីមនុស្សធម៌មួយនៅសណ្ឋាគារ Imperial Garden Villa & Hotel។ ពិធីនេះរៀបចំឡើងគឺដើម្បីស្វែងរក និងប្រមូលមូលនិធិមកគាំទ្រកម្មវិធី GK ដែលជាកម្មវិធីមួយ ក្នុងចំណោមកម្មវិធីជាច្រើនរបស់សហគមន៏ CFC ដើម្បីជួយកសាងផ្ទះជូនគ្រួសារក្រីក្រ សម្រាប់គំរោងឆ្នាំ២០០៧ ខាងមុខនេះ។ ភ្ញៀវកិត្តិយសដែលបានចូលរួមនាឱកាសនោះ រួមមានភ្ញៀវជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ។

កម្មវិធីនេះ ជួយយើងឱ្យចាប់អារម្មណ៏ ពីការចែករំលែកសេចក្តីស្រឡាញ់ និងការសម្តែងធម៌មេត្តាករុណាចំពោះអ្នកក្រីក្រ ដែលកំពុងជួបប្រទះ ការលំបាកខ្វះខាតគ្រប់បែបយ៉ាង ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ក្នុងនាមយើងម្នាក់ៗ ជាបុត្រធីតារបស់ព្រះជាម្ចាស់គឺតែងយកចិត្តទុកដាក់ និងអនុវត្តតាមព្រះបន្ទូលនៃព្រះអង្គ។ ហើយតាមជំនឿរបស់យើង ចំពោះព្រះជាម្ចាស់ ធ្វើឱ្យយើងសម្តែងចេញនូវសកម្មភាពទាំងនេះផងដែរ។

សមាជិកសហគមន៏ CFC ទាំងអស់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួម និងការជួយឧបត្ថម្ភរបស់បងប្អូនចំពោះកម្មវិធី។ សូមឱ្យព្រះយេស៊ូគ្រីស្តជាអម្ចាស់ ប្រទានពរបងប្អូននូវអំណរសប្បាយ និងសេចក្តីសុខសាន្តនាឱកាសបុណ្យព្រះយេស៊ូប្រសូតឆ្នាំនេះ។

ឡុង សម្ផស្ស





## ប្រជុំគណៈកម្មការអប់រំ

ការប្រជុំនេះបានប្រព្រឹត្តទៅនៅថ្ងៃទី២១ វិច្ឆិកា ឆ្នាំ ២០០៦ វេលាម៉ោង ០៨:៣០ ព្រឹកនៅព្រះវិហារផ្សារតូច ដែលមានសិក្ខាកាមប្រមាណ ៣០នាក់ ចូលរួមមកពីអង្គការស្ថាប័ន និងព្រះសហគមន៏ផ្សេងៗ រួមគ្នារិះគិតពីពាក្យអាទិភាពនៃការសិក្សាអប់រំដើម្បីជួយបញ្ជោញយោបល់ធ្វើយ៉ាងណាជំរុញឱ្យការអភិវឌ្ឍន៏ផ្នែកសិក្សាអប់រំព្រះសហគមន៏កាតូលិក ឱ្យមានដំណើរការល្អ និងរីកចម្រើនទៅមុខទៀត។ នៅថ្ងៃប្រជុំនោះ លោកអភិបាលអេមីល ដេតម្ប បានស្វាគមន៏អង្គប្រជុំដោយភាពកក់ក្តៅ និងបានផ្តល់កម្លាំងកាយ ចិត្ត ឱ្យយើងទាំងអស់គ្នាខិតខំបំពេញបេសកកម្មផ្នែកសិក្សាអប់រំព្រះសហគមន៏កាតូលិកដោយសេចក្តីស្រលាញ់ និងសេចក្តីសង្ឃឹម។

លោកឪពុកអូលីវីយេបានធ្វើការពន្យល់អំពីគោលដៅនៃអង្គប្រជុំថ្ងៃនោះដែលមាន៤ គឺ ទី១ : ជួបជុំគ្នាដើម្បីចែករំលែកយោបល់គ្នាទៅវិញទៅមក។ ទី២ : រៀបចំលេខាធិការនៃការសិក្សាអប់រំកាតូលិកភូមិភាគភ្នំពេញ។ ទី៣ : ការបង្កើតឱ្យមានសកលវិទ្យាល័យ និងទី៤ : គឺចាប់ផ្តើមរិះគិតអំពីការរៀបចំឱ្យមាន Forum of Catholic Education ។

សេង អ៊ីង

## ហាងវត្ថុអនុស្សាវរីយ៏ “តាមចិត្ត”



Photo: K. Kagnha

ហាងលក់វត្ថុអនុស្សាវរីយ៏ “តាមចិត្ត” ជាហាងថ្មីមួយ ដែលទើបបង្កើតឡើងដោយព្រះសហគមន៏កាតូលិក ដែលផ្តើមគំនិតដោយលោកបូជាចារ្យអូលីវីយេក្នុងគោលបំណង ដើម្បីជួយដល់ជនក្រីក្រ ខាងផ្នែកសិប្បកម្មខ្មែរ។ ហាងនេះបានត្រូវសម្ពោធកាលពីថ្ងៃទី ៦ ធ្នូ ឆ្នាំ២០០៦ នៅក្រោមអធិបតីភាពលោកអភិបាលភូមិភាគភ្នំពេញអេមីល ដេតម្ប និងមានការចូលរួមពីបណ្តាអង្គការ និងអ្នកតំណាងនៃវិហារកាតូលិកយ៉ាងច្រើនកុះករ។

ហាងទើបនឹងចាប់ផ្តើមបើកនេះមានលក់វត្ថុអនុស្សាវរីយ៏ជាច្រើនប្រភេទមានដូចជា វត្ថុអនុស្សាវរីយ៏ធ្វើពីតម្បាញសូត្រ កាតប៉ូស្តាល់ សៀវភៅពីព្រះសហគមន៏ និងវត្ថុផ្សេងៗជាច្រើនទៀត។ កញ្ញាទាវ វ៉ាន់ថា ជាអ្នកមើលការខុសត្រូវក្នុងហាងនេះ មានប្រសាសន៏ថា : “សម្រាប់ហាងនេះ យើងទទួលតែទំនិញដែលធ្វើនៅក្នុងព្រះសហគមន៏កាតូលិកតែប៉ុណ្ណោះ។ បច្ចុប្បន្ននេះ យើងមានទទួលទំនិញពីអង្គការកាតូលិក និងព្រះសហគមន៏មួយចំនួន មានដូចជា មនុស្សលោកថ្មី ឃ្លេមីតធី មណ្ឌលវប្បធម៏កាតូលិកកម្ពុជា ព្រះសហគមន៏កំពង់ធំ ព្រះសហគមន៏តាកែវ និងព្រះសហគមន៏បាត់ដំបង”។

ទូរស័ព្ទហាង : [illegible]

កែវ កញ្ញា

# អគារសិក្សាថ្មីបំពេញនូវស្នាមញញឹម



Photo: DR

អគារសិក្សាថ្មី មួយខ្នង មាន១០បន្ទប់ អំណោយដ៏ថ្លៃថ្លា ពីលោកឪពុកអូលីវីយេ សហការជាមួយអង្គការ កុមារមេគង្គ ផ្តល់ជូនវិទ្យាល័យ សម្តេចក្រុមព្រះអង្គរនាប នៅភូមិអង្គរនាប ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ។

អគារនេះ បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ២០០៦ ក្រោមអធិបតីភាពរបស់ឯកឧត្តមអ្នកឧកញ៉ាបណ្ឌិតច័ន្ទ សារុន ជារដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីអ្នកតំណាងនៃអង្គការ កុមារមេគង្គ មន្ត្រីរាជការ អាជ្ញាធរដែនដី លោកនាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ហើយនិងប្រជាពលរដ្ឋប្រមាណ ៣០០០នាក់ ផងដែរ។

លោកឪពុកអូលីវីយេ បានមានប្រសាសន៏ ប្រកបដោយសុទិដ្ឋិនិយមថា : “សេចក្តីសង្ឃឹមរបស់ខ្ញុំ គឺថា អគារសិក្សាថ្មីនេះ នឹងធ្វើឱ្យក្មួយៗ ខិតខំរៀនសូត្របានអស់ពីសមត្ថភាពព្រោះការសិក្សាជាកូនសោបើកទ្វារអនាគតឱ្យចាកផុតពីភាពក្រីក្រ”។

បន្ទាប់មកតំណាងអង្គការកុមារមេគង្គបានថ្លែងពីជំហរខ្លួន ជួយកសាងសាលារៀន បណ្ណាល័យ និងផ្តល់លទ្ធភាពដល់សិស្ស និស្សិតក្រីក្រកម្ពុជា។

ឯកឧត្តមអ្នកឧកញ៉ាបណ្ឌិតច័ន្ទ សារុន បានថ្លែងអំណរគុណចំពោះលោកបូជាចារ្យអូលីវីយេ ដែលតែងចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ លោកក៏បានបំពាក់នូវមេដាយស្ថាបនាជាតិ និងផ្តល់ជូននូវលិខិតថ្លែងអំណរគុណជាកិត្តិយសដល់លោកបូជាចារ្យផងដែរ។

លោកគ្រូចាន់ ស៊ាសុន នាយកវិទ្យាល័យសម្តេចក្រុមព្រះអង្គរនាប បានដឹងថា លោករំភើបយ៉ាងខ្លាំង ដោយមានការចូលរួមជួយ និងសហការអំពីព្រះសហគមន៏កាតូលិក។ លោកសូមថ្លែងអំណរគុណយ៉ាងអនេកចំពោះអំណោយដ៏ថ្លៃថ្លានេះ។

ក្នុងនោះដែរ កញ្ញាឡុង ពិសី យុវសិស្សនៃវិទ្យា-ល័យសម្តេចក្រុមព្រះអង្គរនាប បាននិយាយថា : “នេះជាថ្ងៃរំភើបបំផុត ពីព្រោះនាងខ្ញុំមានសាលារៀនល្អ និងសំភារៈសិក្សាទំនើប ពិសេសមានមិត្តសំឡាញ់ល្អបំផុត គឺវិទ្យាល័យសន្តប្រ្សង់ស្វ័រ”។

យុន សំអាត

# មន្ទីរពេទ្យភ្នែកខេត្តតាកែវជួយអ្នកជំងឺគ្រប់វណ្ណៈ


Photo: M. Kunthear
អ្នកជំងឺភ្នែក

មន្ទីរពេទ្យភ្នែកនេះបង្កើតក្នុងឆ្នាំ១៩៩៧ ដោយលោកបូចារ្យ Jonh Ba ជនជាតិអាម៉េរិកក្នុងបំណងជួយអ្នកក្រីក្រដែលមានជំងឺភ្នែកទាំងចាស់ក្មេងក្រោមការឧបត្ថម្ភរបស់អង្គការម៉ារីណុល (ឆ្នាំ១៩៩៧-២០០០) និងបន្តជួយដោយអង្គការការីតាសកម្ពុជាវិញ និងសហការជាមួយរដ្ឋាភិបាលផងដែរ។

ជំងឺភ្នែកគឺជាជំងឺ ដែលកើតមានឡើងដល់មនុស្សគ្រប់វ័យ។ បើយោងទៅតាមស្ថិតិនៃមន្ទីរពេទ្យភ្នែក ខេត្តតាកែវ ដែលបង្ហាញដោយ លោកតែ សេរីបុណ្យ ប្រធានរដ្ឋបាលនៃមន្ទីរពេទ្យបានឱ្យដឹងថា ចាប់តាំងពីឆ្នាំ១៩៩៧ រហូតដល់បច្ចុប្បន្ន មន្ទីរពេទ្យបានទទួលអ្នកជំងឺភ្នែកកើនឡើងជាលំដាប់ ដែលមាន៩៩% ជាប្រជាជនក្រីក្រ។ អ្នកជំងឺមកព្យាបាលនៅនេះមានជំងឺផ្សេងៗគ្នា ហើយភាគច្រើនជាងគេ ជាមនុស្សចាស់ដែលមានវ័យចាប់ពី ៤៥ឆ្នាំឡើងទៅ។

កំពុងតែអង្គុយនៅលើគ្រែនិយាយជាមួយបងប្អូន ដែលមកសាកសួរសុខទុក្ខ ព្រមទាំងអមដោយគ្រែនៃអ្នកជំងឺផ្សេងៗទៀតជាច្រើនដែរ លោកឃិន សោ ដែលមានមុខរបរជាអ្នករត់ម៉ូតូឌុបបានមកសម្រាកព្យាបាលជំងឺរលាកកែវភ្នែក នៅមន្ទីរពេទ្យតាកែវនេះ អស់រយៈពេលជាងមួយសប្តាហ៍ មកហើយ។ លោកបានឱ្យដឹងថា គាត់មកទីនេះ ដោយសារឮគេនិយាយតៗគ្នាអំពីមន្ទីរពេទ្យនេះ។ អ្នកជំងឺដដែលនេះក៏បានប្រាប់បន្ថែមទៀតថា គាត់មានការលំបាកទម្រាំបានចូលមកព្យាបាល ព្រោះគាត់ត្រូវតម្រង់ជួរចាប់លេខ ចូលទៅពិនិត្យភ្នែក និងបង់នូវថ្លៃសេវាកម្មតាមលទ្ធភាពរបស់គាត់ជូនដល់មន្ទីរពេទ្យនេះ។ តម្លៃកំណត់គឺ ៦ម៉ឺនរៀល បើយើងអត់ គេអាចយក ជួនកាលពី២ ៣ ឬ៤ម៉ឺន។ មន្ទីរពេទ្យបានផ្តល់ថ្នាំឱ្យដល់គាត់សម្រាប់ដាក់ភ្នែកដោយមិនគិតថ្លៃ។

លោកតែ សេរីបុណ្យ បានគូសបញ្ជាក់ថា នៅក្នុងមន្ទីរពេទ្យរបស់យើង មានការរៀបចំជាប្រព័ន្ធមួយ ដោយមានការធ្វើការសហការជាមួយរដ្ឋាភិបាលផងដែរ។ បុគ្គលិកមួយចំនួនដែលធ្វើការនៅទីនេះជារបស់រដ្ឋាភិបាល និងខ្លះទៀតមកពីអង្គការការីតាស។ រដ្ឋាភិបាលបានផ្តល់ឱ្យដល់បុគ្គលិក នូវទីកន្លែងស្នាក់នៅ ផ្តល់អគ្គិសនី និងទឹកដើម្បីជួយឱ្យមន្ទីរពេទ្យដំណើរការបាន។ ក្រៅពីនេះ អង្គការគឺជាអ្នកផ្តល់ជូន មានថ្នាំសង្កូវ ថវិកាចំណាយផ្សេងៗ ព្រមទាំងប្រាក់បៀវត្សរបស់បុគ្គលិកទៀតផង។ លោកតែ សេរីបុណ្យ ក៏បានធ្វើការលើកឡើងបន្ថែម ទៅលើការបង់ថ្លៃសេវាកម្ម ឬក៏ការធ្វើហិរញ្ញប្បទានចំពោះមន្ទីរពេទ្យនេះថា មន្ទីរពេទ្យពុំបានទាមទារឱ្យអ្នកជំងឺបង់ថ្លៃដូចដែលបានកំណត់ក្នុងតារាងនោះទេ នេះវាអាស្រ័យលើសមត្ថភាពរបស់អ្នកជំងឺផ្ទាល់ ហើយមន្ទីរពេទ្យផ្តល់សេវាកម្មដល់អ្នកជំងឺគ្រប់វណ្ណៈ ផ្តល់សិទ្ធិស្មើៗគ្នា ទាំងអ្នកមាន និងអ្នកក្រ ហើយចំណែកអ្នកដែលមានសមត្ថភាពច្រើនពួកគាត់គឺអាចបង់ថ្លៃឱ្យគ្រប់ ដើម្បីជួយដល់អ្នកក្រីក្រដែលគាត់មិនមានលទ្ធភាពបង់ថ្លៃ ប៉ុន្តែ អ្នកដែលមានលទ្ធភាពទាំងនោះគឺមានប្រមាណតែ ១%ប៉ុណ្ណោះ។

លោកយាយ អាយុ៧៤ឆ្នាំ អ្នកស្រុកភូមិរស់ក្បែរមន្ទីរពេទ្យភ្នែកខេត្តតាកែវនេះ បានមកសម្រាកព្យាបាល ដោយលោក...

### មន្ទីរពេទ្យភ្នែកតាកែវ

មានសេវាកម្ម ពិគ្រោះ ការវះកាត់ ការផ្តល់នូវការវាស់វ៉ែនតា និងការសម្រាកក្រោយពេលវះកាត់រួច។ មន្ទីរពេទ្យនេះមានគ្រូពេទ្យជំនាញ ៣ នាក់ ជនបរទេសម្នាក់ គិលានុបដ្ឋាយិកា ១៦ នាក់ និងជនបរទេសអ្នកសម្របសម្រួលម្នាក់។ មន្ទីរពេទ្យឋិតនៅក្នុងស្រុកដូនកែវ ខេត្តតាកែវ។


Photo: M. Kunthear
អ្នកជំងឺកំពុងសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យភ្នែកខេត្តតាកែវ

...យាយមានជំងឺភ្នែកឡើងបាយ ហើយក៏ទើបនឹងវះកាត់រួច។ គាត់បានឱ្យដឹងថា ភ្នែកគាត់ចាប់ផ្តើមឈឺខ្លាំង មុនពេលមកព្យាបាលនៅមន្ទីរពេទ្យនេះ២-៣ថ្ងៃប៉ុណ្ណោះ ទោះជាលោកយាយធ្វើអ្វីក៏មិនអាចបាត់នោះដែរ។

“ភ្នែករបស់ខ្ញុំឈឺសូម្បីតែដេកក៏មិនបាន អង្គុយក៏មិនបាត់ ខ្ញុំឱ្យបងស្រីរបស់ខ្ញុំបន់ស្រន់ព្រះ តែនៅតែឈឺ”។ លោកយាយមានប្រសាសន៍ទាំងយកដៃបិទភ្នែកឆ្វេងដែលឈឺ។ គាត់បន្តថា គ្រូពេទ្យនៅទីនេះ យកចិត្តទុកដាក់ចំពោះអ្នកជំងឺណាស់ ទឹកមុខពួកគេរួសរាយរាក់ទាក់ និងសំដីពិរោះ។ ពួកគេមិនទាមទារសារគុណអំពីលោកយាយឡើយ ថែមទាំងឱ្យនូវថ្នាំពេទ្យ និងវះកាត់ភ្នែកឆ្វេងរបស់គាត់។ ប៉ុន្តែស្ត្រីចំណាស់៧៤ឆ្នាំរូបនេះបានបញ្ជាក់ថា ទោះជាយ៉ាងណាក៏គាត់សុំគ្រូពេទ្យបង់ជាវិភាគទានចំនួន ២០០០០រៀលផងដែរ។

លោកស៊ុន សារិន ដែលជាវេជ្ជបណ្ឌិតខាងផ្នែកភ្នែកបានមានប្រសាសន៍ឱ្យដឹងថា: “មន្ទីរពេទ្យនេះគឺគិតទៅលើគុណភាពជាចម្បង ទន្ទឹមនឹងមានការកើនឡើងនូវជំងឺភ្នែកជាលំដាប់ផងដែរ”។ និយាយដោយយកចិត្តទុកដាក់ និងមានភាពម៉ឺងម៉ាត់ លោកបន្តថា ការវះកាត់របស់ក្រុមលោកទទួលបាននូវជោគជ័យជាច្រើនលើកច្រើនសាមកហើយ ដោយលោក និងគ្រូពេទ្យទាំងឡាយឯទៀតៗ បានហ្វឹកហាត់អស់ជាច្រើនឆ្នាំ និងបានទទួលនូវការបណ្តុះបណ្តាល ពីពេទ្យជំនាញបរទេសព្រមជាមួយគ្នានេះ លោកបានទៅសិក្សាបន្ថែមនៅប្រទេសក្រៅទៀតផង។ គ្រូពេទ្យទាំងអស់គឺតែងមាននូវស្មារតីប្រុងប្រយ័ត្នយ៉ាងខ្លាំងចំពោះការថែទាំអនាម័យ ដើម្បីកុំឱ្យមានមេរោគចម្លងទៅដល់អ្នកជំងឺនៅពេលវះកាត់។

លោកបន្តទៀតថា ការលំបាកក្នុងការវះភ្នែក គឺវាអាស្រ័យទៅលើជំងឺ បើភ្នែកនោះមានអាការៈខ្លាំង វាពិបាក ប៉ុន្តែបើស្រាលគឺវាងាយស្រួល។ យ៉ាងណាមិញ វាងាយស្រួលច្រើនជាងកាលពីមុន ពីព្រោះយើងមានឧបករណ៍ទំនើបៗក្នុងការពិនិត្យភ្នែក។ លោកបន្តសំដីថា បើប្រៀបធៀបទៅនឹង ១០ ឆ្នាំមុននោះ គឺការវះភ្នែកមានការលំបាកណាស់ តែនៅពេលបច្ចុប្បន្ននេះវិញ ការវះភ្នែកមានលក្ខណៈងាយស្រួល ព្រោះតែគ្រូពេទ្យរបស់យើងគឺមានវិជ្ជាជីវៈ យ៉ាងស្ទាត់ជំនាញ និងមានបទពិសោធន៍ច្រើនទៀតផងដែរ។

មុំ គន្ធា និងកញ្ញា



Photo: DR

## និយាយអំពីរាជាណាចក្រប្រ៊ុយណេ

ក្រោមការដឹកនាំរបស់ព្រះចៅអធិរាជស៊ុលតង់ បានធ្វើឱ្យប្រទេសប្រ៊ុយណេ ឈានដល់កម្រិតកំពូល នៅចន្លោះសតវត្សរ៍ទី១៥ និងទី១៧ នៅពេលដែលមានការពង្រីកការគ្រប់គ្រងរបស់ខ្លួនពាសពេញតំបន់ឆ្នេរ Borneo នៃភាគខាងត្បូងរបស់ប្រទេសហ្វីលីពីន។ ក្រោយៗមក ប្រទេសប្រ៊ុយណេមានការចុះខ្សោយជាខ្លាំង ដោយសារតែមានជម្លោះអន្តរជាតិបានកើតមានពាសពេញរាជាណាចក្ររបស់ខ្លួន ការពង្រីកដែនដីអាណានិគមរបស់ពួកអឺរ៉ុប និងអំពើលួចប្លន់តាមដែនសមុទ្រ។ នៅឆ្នាំ១៨៨៨ ប្រទេសប្រ៊ុយណេ បានក្លាយជាទឹកដីអាណានិគមរបស់ចក្រភពអង់គ្លេស។ តែក្រោយមកនៅឆ្នាំ១៩៨៤ ប្រទេសប្រ៊ុយណេទទួលបានឯករាជ្យពីប្រទេសអង់គ្លេសមកវិញ។

ក្នុងអំឡុងជាង ៦សតវត្សរ៍ ប្រទេសប្រ៊ុយណេ ត្រូវបានគ្រប់គ្រងដោយរាជ្យវង្សក្សត្រតែមួយ និងបានទាញយកប្រយោជន៍ ជាច្រើនក្នុងការអភិវឌ្ឍន៍ប្រទេសជាតិពីវិស័យប្រេងកាត និងឧស្ម័នធម្មជាតិ ហើយមានតម្លៃថ្លៃលើទីផ្សារអន្តរជាតិ ព្រមទាំងជាប្រភពដ៏ធំបំផុតមួយក្នុងការផ្គត់ផ្គង់ដល់ការអភិវឌ្ឍន៍ពិភពលោកទៀតផង។

### ទិន្នន័យសំខាន់ៗ

**ចំនួនប្រជាជន**: ៣៧៩៤៤៤ លាននាក់ (ទិន្នន័យខែកក្កដា ឆ្នាំ២០០៦)។ **ជាតិសាសន៍ផ្សេងៗ**: ជនជាតិម៉ាឡេ ៦៧% ជនជាតិចិន ១៥% ជនអន្តោប្រវេសន៍ ៦% និងជាតិសាសន៍ដទៃទៀត ១២%។ **ភាសា**: ម៉ាឡេ (ភាសាផ្លូវការ) អង់គ្លេស និងចិន។ **សាសនា**: ម៉ូស្លីម (សាសនារបស់រដ្ឋ) ៦៧% សាសនាព្រះពុទ្ធ ១៣% គ្រីស្តសាសនា ១០% ជំនឿលើអន្តោគ្រាមសាសនា និងសាសនាដទៃៗ ១០%។ **ផ្ទៃដី**: ៥៧៧០ គីឡូម៉ែត្រការ៉េ។ **ធនធានធម្មជាតិ**: ប្រេងកាត ឧស្ម័នធម្មជាតិ និងព្រៃឈើ។ **អាកាសធាតុ**: ស្ថិតនៅក្នុងតំបន់ត្រូពិចក្តៅ ហើយសើម និងមានកម្តៅគ្រប់គ្រាន់។ **របបដឹកនាំប្រទេស**: រាជាណាចក្រស៊ុលតង់អាស្រ័យរដ្ឋធម្មនុញ្ញ។ **រូបិយវត្ថុ**: ដុល្លារប្រ៊ុយណេ។ **ឯករាជភាព**: ថ្ងៃ១ មករា ឆ្នាំ១៩៨៤ ពីចក្រភពអង់គ្លេស។

# ថ្ងៃខួប៤៥០ឆ្នាំនៃព្រះសហគមន៍កាតូលិក

**មនុស្សម្នាប្រមាណជាជាង ២ពាន់នាក់ បានធ្វើដំណើរមកពីគ្រប់ព្រះសហគមន៍នៅទូទាំងប្រទេសកម្ពុជា ជួបជុំគ្នាដើម្បីប្រារព្ធខួប៤៥០ឆ្នាំនៃព្រះសហគមន៍កាតូលិកនៅកម្ពុជា ដែលបានប្រារព្ធឡើងនាថ្ងៃទី៣ ធ្នូ ២០០៦ នៅព្រះវិហារតាំងគោកក្នុងខេត្តកំពង់ធំ ដែលជាកន្លែងនឹករលឹកដល់អស់ទាំងមរណសាក្សីនៅក្នុងប្រទេសកម្ពុជា។**





Photo: S. Philong



Photo: P. Samphy



Photo: L. Sovanna



លោកអភិបាលគីកេ បូជាចារ្យ និងគ្រីស្តបរិស័ទព្រោះស្រូវ នៃជំនឿលើផ្នូរមរណសាក្សី

Photo: S. Philong

នេះជាលើកទីមួយ ដែលព្រះសហគមន៍កាតូលិកនៅកម្ពុជា ប្រារព្ធធ្វើពិធីបុណ្យមួយដ៏ធំ ដែលមិនធ្លាប់មានកន្លងមក។ អាចនិយាយបានថា នេះជាប្រវត្តិសាស្ត្រមួយនៃព្រះសហគមន៍កាតូលិកនៅកម្ពុជា។ គោលបំណងរបស់កម្មវិធីនោះ គឺដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រោសប្រទានឱ្យប្រទេសកម្ពុជាមានប្រជាជនខ្លះ បានស្គាល់ព្រះយេស៊ូ ហើយបានរស់នៅជាព្រះសហគមន៍ និងធ្វើជាសាក្សីបន្ទាល់ នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងអស់។

របាំក្ងោកនៃក្រុមសិល្បៈព្រះសហគមន៍ បឹងទំពុន បានរាំយ៉ាងទន់រំពៃននាំមុខក្បួនដង្ហែរបស់លោកអគ្គរាជទូត លោកអភិបាល លោកបូជាចារ្យ និងគ្រីស្តបរិស័ទ ជាច្រើនរូបទៀត។ ស្របពេលនោះដែរ លោកអគ្គរាជទូតបានធ្វើដំណើរមួយជុំដើម្បីបាចទឹកព្រះពរដល់គ្រីស្តបរិស័ទដែលមានវត្តមានក្នុងពិធីនោះផងដែរ។ កំពុងអង្គុយនិយាយលេងជាមួយមិត្តភក្តិចាស់ និងបង្កប់ដោយស្នាមញញឹមបញ្ចេញនូវភាពសប្បាយ កញ្ញាដួង ចំន្ទធីតា មកពីព្រះសហគមន៍សៀមរាប បង្ហាញអំពីអារម្មណ៍រីករាយ និងរំភើបដែលបានមកចូលរួមក្នុងឱកាសនោះ ពិសេស កម្មវិធីនេះមានលក្ខណៈប្លែក ដែលពុំធ្លាប់ឃើញមាននៅព្រះសហគមន៍សៀមរាប។ កញ្ញា ប្រាប់ថា វាមានលក្ខណៈប្លែកច្រើនសម្រាប់រូបនាង ដោយនាងបានស្គាល់ព្រះវិហារតាំងគោក បានជួបមិត្តភក្តិចាស់ៗ ដែលបានបែកគ្នាយូរ និងមានការថ្វាយអភិបូជា ដែលមានមនុស្សជាច្រើនដែលនាងមិនដែលឃើញ និងបានចូលរួម។

លោកអភិបាល ភូមិភាគភ្នំពេញ អេមីល ដេតម្បូ បានមានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទនិងភ្ញៀវកិត្តិយសក្នុងពិធីប្រកបដោយអត្ថន័យខ្លង់ខ្លស់នេះថា: “ពិធីបុណ្យថ្ងៃនេះ គឺមិនមែនគ្រាន់តែជាពិធីបុណ្យនឹករលឹកដល់ប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែវាជាការត្រាស់ហៅមួយឱ្យយើងបន្តបេសកកម្ម នៃព្រះគ្រីស្ត ជាព្រះអម្ចាស់ ដែលទ្រង់បានប្រគល់ ឱ្យក្រុមគ្រីស្តទូត មុនពេលដែលព្រះអង្គបានចេញពីពួកគេ”។ ចូរយើងនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល ហើយប្រកាសដំណឹងល្អទៅដល់គ្រប់មនុស្សលោកទាំងអស់។ លោកអិល ឈិញ គឺជាអ្នកទទួលខុសត្រូវនៃមណ្ឌលយុវជនបច្ចេកទេសព្រះសហគមន៍កាតូលិក បឹងត្របែក មានប្រសាសន៍ ក្នុងវេលាព្រឹកនោះដែរថា: “នេះគឺជាកម្មវិធីដ៏អស្ចារ្យសម្រាប់ព្រះសហគមន៍កាតូលិក នៅកម្ពុជា”។ លោកបន្តថា ការធ្វើបែបនេះគឺជាឱកាសមួយសម្រាប់គ្រីស្តបរិស័ទទាំងអស់មកជួបជុំគ្នារំលឹកដល់អតីតកាលដែលព្រះសហគមន៍ចូលមកស្រុកខ្មែរ។

ក្រោយពីសម្រាកញុំាអាហារថ្ងៃត្រង់ និងមានការច្រៀងលេងកំសាន្តរបស់ក្រុមយុវជន ប្រមាណជា ២ម៉ោង លោកអគ្គរាជទូត លោកបូជាចារ្យ គ្រីស្តបរិស័ទពីគ្រប់ភូមិភាគ បានមកជួបជុំគ្នាម្តងទៀតដើម្បីរៀបចំពិធីពិសេសមួយទៀត គឺពិធីបាចទឹកព្រះពរលើស្តូបអនុស្សាវរីយ៍ផងដែរ។

អ្នកនាងចាន់ សេរី ដែលមើលទៅហាក់ដូចជាហត់នឿយបន្តិច តែផ្ទៃមុខនៅតែស្រស់ស្រាយជានិច្ច បាននិយាយថា នេះជាលើកទីមួយ ដែលគាត់បានចូលរួម ហើយគាត់មានអារម្មណ៍សប្បាយរីករាយមែនទែន។ អ្នកនាងចាន់ សេរី និយាយថា: “ខ្ញុំដឹងថាព្រះសហគមន៍កើតមានពីយូរ តែពុំដឹងថាប៉ុន្មានឆ្នាំទេ ទើបតែថ្ងៃនេះបានដឹងច្បាស់”។

អត្ថបទដោយមុំ គន្ធា

## ព្រះសហគមន៍កាតូលិក

មាននៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៥៥៥មក និងឥឡូវចែកចេញជា៣ភូមិភាគ ដែលភូមិភាគនីមួយៗ មានព្រះសហគមន៍តូចៗជាច្រើនទៀត។ យោងតាមស្ថិតិនៃអង្គសន្និបាតកាលពីខែកក្កដា ២០០៦ ភូមិភាគភ្នំពេញមាន ៣២ព្រះសហគមន៍ ភូមិភាគកំពង់ចាមមាន ២២ព្រះសហគមន៍ និងភូមិភាគបាត់ដំបងមាន ២៥ព្រះសហគមន៍ ដែលគ្រីស្តបរិស័ទសរុបមានជាង ២ម៉ឺននាក់។



# ព្រះបន្ទូលបានកើតជាមនុស្ស ហើយគង់ក្នុងចំណោមយើង

**នាឱកាសបុណ្យខួប៤៥០ឆ្នាំ នៃព្រះសហគមន៍កាតូលិកនៅកម្ពុជា លោកអភិបាលសាលវ៉ាទ័រេ ពេណ្ណាស៊ីយ៉ូ តំណាងខ្ពង់ខ្ពស់សម្តេចប៉ាបបេណេឌីកតូទី១៦ បានថ្លែងសុន្ទរកថាដូច្នេះថា:**



លោកអភិបាលសាលវ៉ាទ័រេ ពេណ្ណាស៊ីយ៉ូ

Photo: P. Samphy

ខ្ញុំមានអំណរសប្បាយរីករាយយ៉ាងខ្លាំងដែលបានមកកាន់ព្រះរាជាណាចក្រកម្ពុជាក្នុងនាមសម្តេចប៉ាបបេណេឌីកតូទី១៦ ដើម្បីធ្វើជាអធិបតីក្នុងពិធីដ៏វិសុទ្ធ និងយ៉ាងឱឡារិកនេះ។ ពិធីអរព្រះគុណដ៏វិសុទ្ធជាប្រភព និងជាកំពូលបេសកកម្មទាំងមូល នៃព្រះសហគមន៍កាតូលិក ហើយនៅក្នុងពិធីអរព្រះគុណដ៏វិសុទ្ធព្រះសហគមន៍ទាំងមូលថ្វាយជីវិតរបស់ខ្លួនដើម្បីឈានទៅមុខ ដោយសេចក្តីអង់អាចក្លាហាន ស្មោះត្រង់ និងព្យាយាមយ៉ាងមុតមាំ។

ពិធីបុណ្យខួប ៤៥០ឆ្នាំនេះ ស្របគ្នានឹងបុណ្យសំខាន់នៅក្នុងព្រះសហគមន៍ គឺក្នុងអាទិត្យទី ១ ក្នុងរដូវអបអរសាទរព្រះយេស៊ូយាងមក។ ពេលដែលយើងទាំងអស់គ្នា រៀបចំចិត្តគំនិតអបអរសាទរបុណ្យព្រះយេស៊ូប្រសូត ឬក៏អបអរព្រះកុមារយេស៊ូ ដែលកើតជាមនុស្សដើម្បីសម្តែងព្រះហឫទ័យស្រលាញ់ មិនចេះរីងស្ងួតរបស់ព្រះបិតាចំពោះយើងទាំងអស់គ្នា។

ពេលនេះ ខ្ញុំសូមជូនពរបងប្អូនក្នុងពិធីបុណ្យដ៏ប្រសើរនេះ។ ខ្ញុំក៏មានកិត្តិយសអានសាររបស់សម្តេចប៉ាបបេណេឌីកតូ ទី១៦ ដែលនិយាយមកកាន់បងប្អូន តាមរយៈលោកអភិបាលទីប្រឹក្សាសម្តេចប៉ាប និងលោកអភិបាលអេមីលដេតម្បូ ក្នុងឱកាសខួប ៤៥០ឆ្នាំនេះ។

បុណ្យខួប ៤៥០ឆ្នាំ នៃវត្តមានព្រះសហគមន៍កាតូលិក នៅកម្ពុជា សម្តេចប៉ាបបេណេឌីកតូទី១៦ សូមចូលរួមយ៉ាងរីករាយជាមួយលោកអភិបាលភូមិភាគទាំងបី អស់លោកបូជាចារ្យ បព្វជិត បព្វជិតា និងបងប្អូនគ្រីស្តបរិស័ទទាំងអស់នៅទូទាំងប្រទេសកម្ពុជា លើកតម្កើងអរព្រះគុណព្រះជាអម្ចាស់។ សម្តេចប៉ាបសូមជូនពរបងប្អូន ដែលបានទទួលពិធីជ្រមុជទឹកទាំងអស់ និងឱ្យយកចិត្តទុកដាក់រំឭកឡើងវិញអំពីប្រវត្តិរបស់គ្រីស្តបរិស័ទលើទឹកដីកម្ពុជា ដែលប្រកបដោយអំណោយផល យ៉ាងទូលំទូលាយ និងវីរភាពរបស់អ្នកគង្វាល។ គ្រីស្តបរិស័ទជាច្រើនបានប្រព្រឹត្តនៅក្នុងជីវិតរស់នៅរបស់ពួកគាត់ដើម្បីប្រកាសព្រះបន្ទូលព្រះជាម្ចាស់។

សូមព្រះគ្រីស្ត ដែលមានព្រះជន្មថ្មី ដ៏រុងរឿងប្រទាននូវសេចក្តីសង្ឃឹមយ៉ាងមុតមាំដល់គេ។ សូមអបអរដល់អស់បងប្អូនដែលបំរើព្រះសហគមន៍ និងបំរើសង្គមជាតិ ពិសេសក្នុងក្របខណ្ឌអប់រំបណ្តុះបណ្តាល។ សម្តេចប៉ាបក៏សូមលើកទឹកចិត្តបងប្អូនគ្រីស្តបរិស័ទទាំងអស់ ឱ្យស្វាហាប់ ដើរតាមបុព្វបុរសនៃជំនឿយើង ជាសាវ័ករបស់ព្រះគ្រីស្ត ដែលក្នុងដំណើរជីវិតនៃពួកគាត់ គឺប្រកាសពីសេចក្តីស្រលាញ់ដ៏ធំធេងអស្ចារ្យនៃព្រះជាម្ចាស់ ដោយគោរពរាប់អានដែលបុព្វបុរសរបស់យើង បានប្រព្រឹត្តចំពោះបងប្អូនគ្រប់ៗគ្នា។ សម្តេចប៉ាប សូមអញ្ជើញយើងទាំងអស់គ្នាឱ្យយកគំរូតាមព្រះនាងម៉ារី ដើម្បីទទួលព្រះយេស៊ូជាព្រះបុត្រានៃព្រះជាម្ចាស់ ឱ្យគង់ជានិច្ចក្នុងចិត្តនៃយើងម្នាក់ៗ និងផ្តល់សេរីភាពយ៉ាងត្រចះត្រចង់ផងដែរ។

# ប្រិមប្រិយ: "ព្រះយេស៊ូជាពន្លឺបំភ្លឺយើងទាំងអស់គ្នា"

**បុណ្យព្រះយេស៊ូប្រសូត្រជិតឈានមកដល់ហើយ។ កញ្ញាស៊ើ ប្រិមប្រិយ គ្រីស្តបរិស័ទបានចាប់អារម្មណ៍ចំពោះពិធីបុណ្យណូអែលនៅព្រះសហគមន៍កំពង់ចាម។**

តើនាងមានអារម្មណ៍ និងមតិយ៉ាងណាខ្លះចំពោះពិធីបុណ្យដ៏មានអត្ថន័យសម្រាប់ព្រះសហគមន៍កាតូលិក?

"នៅពេលខែវិច្ឆិកាចាប់ចូលមកដល់ ពេលដែលខ្ញុំភ្ញាក់ពីគេង និងមានខ្យល់បក់ខ្លាំង ធ្វើឱ្យខ្ញុំទទួលអារម្មណ៍ថា បុណ្យណូអែល ជិតមកដល់ហើយ។ ខ្ញុំមានអារម្មណ៍ ដូចជាបានទទួលព្រះកុមារយេស៊ូមកក្នុងជីវិតរបស់ខ្ញុំ"។ សំឡេងស្រួយស្រែសបានលាន់ឮយ៉ាងរណ្តំ ហាក់ដូចជាចង់ឱ្យបុណ្យណូអែលឆាប់មកដល់របស់កញ្ញាស៊ើ ប្រិមប្រិយ។

កញ្ញាបង្ហាញពីចំណាប់អារម្មណ៍ និងហេតុការណ៍មួយចំនួនទាក់ទងនឹងបុណ្យ ព្រះយេស៊ូប្រសូត ឬបុណ្យណូអែលនៅព្រះសហគមន៍កំពង់ចាមថា: ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត្រ ឬបុណ្យណូអែល យើងបានជួបជុំបងប្អូនគ្រីស្តបរិស័ទដ៏ច្រើនកុះករ និងមនុស្សម្នាដែលមកពីស្ទើរគ្រប់ព្រះសហគមន៍ក្នុងភូមិភាគកំពង់ចាម ដើម្បីសួរសុខទុក្ខ និងចូលរួមលេងសប្បាយជាមួយគ្នា។

ផ្ទុយមកវិញ បើមានគ្រីស្តបរិស័ទ ដែលជាប់រវល់ខ្លាំង ឬមិនបានមកព្រះវិហារក្នុងឱកាសនោះ ពួកគេក៏គ្មានទោសអ្វីទេ។ តាមពិតអត្ថន័យរបស់ពិធីបុណ្យណូអែល គឺវាស្ថិតនៅក្នុងចិត្តរបស់យើងជារៀងរាល់ថ្ងៃ។ ម្យ៉ាងទៀត ពិធីដែលយើងធ្វើនៅថ្ងៃនោះគឺ: "ព្រះយេស៊ូជាពន្លឺ បំភ្លឺយើងទាំងអស់គ្នា"។ ព្រះជាម្ចាស់បានផ្តល់អ្វីៗ ទាំងអស់ឱ្យយើងតាមរយៈព្រះយេស៊ូ។

កញ្ញាក៏ចាប់អារម្មណ៍ទៀតថា សម្រាប់បងប្អូនខ្លះដែលមិនមែនជាគ្រីស្តបរិស័ទ ប៉ុន្តែពួកគេបានចូលរួមយ៉ាងសប្បាយ នៅក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតដែរ។ អ្វីដែលល្អទោះជាគេមិនយល់ យ៉ាងហោចណាស់ ក្នុងថ្ងៃនោះ គេចេះចែករំលែកកាដូឱ្យគ្នាដើម្បីបញ្ជាក់ពីសេចក្តីស្រលាញ់ផងដែរ។

យើងចង់បើកឱ្យទូលាយ ដើម្បីឱ្យគេស្គាល់យើងកាន់តែច្បាស់ ព្រោះកន្លងមកមានអ្នកខ្លះនិយាយថា អ្នកកាន់គ្រីស្តសាសនាមិនចេះគោរពម៉ែឪ មិនប្រើទៀនធូបផ្កា និងខ្លះទៀតថា យើងប្រកាន់មិន[illegible]

បូរ៉ា


Photo: Fr. Ivan

# លោកអ៊ីវ៉ាន់: "អបអរព្រះអម្ចាស់យាងមក"


Photo: M. Kunthear

លោកបូជាចារ្យអ៊ីវ៉ាន់ ដែលនឹងត្រូវទៅបំពេញ បេសកកម្មបំរើព្រះសហគមន៍កំពង់ចាមនាចុងឆ្នាំ២០០៦នេះ បានមានប្រសាសន៍ពីអត្ថន័យ និងបទពិសោធន៍មួយចំនួននៃពិធីបុណ្យរដូវរង់ចាំនៅក្នុងប្រទេសអេក្វាទ័រដែលជាប្រទេសកំណើតរបស់លោក ដែលមានអត្ថន័យដូចខាងក្រោម:

ឆ្នាំនេះ ព្រះសហគមន៍កាតូលិកប្រារព្ធពិធីបុណ្យរង់ចាំព្រះយេស៊ូយាងមក។ នៅក្នុងថ្ងៃនោះ ព្រះសហគមន៍កាតូលិកមានគោលបំណងតាស់តឿនគ្រីស្តបរិស័ទ ឱ្យសញ្ជឹងគិតអំពីព្រះយេស៊ូដែលមានព្រះជន្មគង់នៅជាមួយពួកគេ។ ព្រះសហគមន៍កាតូលិកប្រារព្ធពិធីបុណ្យរដូវរង់ចាំព្រះយេស៊ូយាងមកលើកនេះដើម្បីបង្ហាញពីទំនាក់ទំនងមនុស្សជាមួយព្រះយេស៊ូគ្រីស្ត។ ពាក្យថា Advent : មកពីពាក្យថា Ad venio មានន័យថា: "យាងមក"។ ដូច្នេះពាក្យថា Advent មានន័យថា: "ព្រះយេស៊ូយាងមក"។ ការរង់ចាំរបស់គ្រីស្តបរិស័ទចំពោះការប្រសូតរបស់ព្រះយេស៊ូគ្រីស្តគឺពោរពេញដោយព្រះហឫទ័យប្រណីសណ្តោស ក្តីសង្ឃឹម និងការលើកលែងទោស។ ចូរយើងរាល់គ្នាទទួលស្គាល់ព្រះយេស៊ូគ្រីស្តជាបុត្រារបស់ព្រះជាម្ចាស់ និងជាព្រះសង្គ្រោះដែលមានសេចក្តីស្រលាញ់មេត្តាចំពោះយើងរាល់គ្នា និងសេចក្តីសុខសប្បាយ។ ក្នុងរដូវរង់ចាំព្រះយេស៊ូយាងមកព្រះសហគមន៍កាតូលិកប្រើពណ៌ស្វាយ ដែលនេះមានអត្ថន័យថា ចម្រៀងលើកលែងទោស និងការទទួលកំហុសរបស់មនុស្សដែលបានប្រព្រឹត្តចំពោះព្រះជាម្ចាស់។ ដូច្នេះនៅក្នុងបុណ្យរដូវរង់ចាំនេះ គ្រីស្តបរិស័ទទទួលបាននូវការលើកលែងទោស និងរស់នៅដោយសេចក្តីសុខសប្បាយ។

បុណ្យរង់ចាំព្រះយេស៊ូយាងមកប្រារព្ធធ្វើរយៈពេល៤សប្តាហ៍ មុនថ្ងៃបុណ្យណូអែល។ នៅថ្ងៃអាទិត្យនៃសប្តាហ៍ទី១ នៃរដូវរង់ចាំព្រះយេស៊ូយាងមកនោះ ព្រះសហគមន៍ក៏កត់សម្គាល់លើការចាប់ផ្តើមឆ្នាំថ្មីនៃរដូវរង់ចាំ និងការផ្លាស់ប្តូរទស្សនៈរបស់អ្នកអាន។ នៅក្នុងប្រពៃណីមួយរបស់ជនជាតិអេស្ប៉ាញ បានរៀបរាប់ពីដំណើរជីវិតនាងម៉ារី និងលោកយ៉ូសែបដែលធ្វើដំណើរពីភូមិណាសារ៉ែតទៅកាន់បេថ្លេហិម និងការស្នាក់នៅផ្ទះមួយនៅតាមដងផ្លូវ ឬនៅក្នុងព្រះវិហារ។ ពិធីបុណ្យប្រារព្ធឡើងមានរយៈពេល៩ថ្ងៃ គឺចាប់ពីថ្ងៃទី១៦-២៤ ខែធ្នូ តំណាងឱ្យការមានគភ៌របស់នាងម៉ារី និងមានក្រុមមនុស្សមួយក្រុមធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយនៅតាមដងផ្លូវ ហើយឃើញអ្នកមានបុណ្យនៅក្នុងផ្ទះនោះ។

បូជាចារ្យអ៊ីវ៉ាន់





**ការយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ អ្នកត្រូវគេរើសអើង អ្នកជំងឺអេដស៍ជាដើម គឺជាកិច្ចការចម្បងរបស់ក្រុមគ្រួសារបងប្រុសមេត្តាករុណា ដែលតែងតែអនុវត្តតាមព្រះបន្ទូល និងយកគំរូរបស់អ្នកម្តាយតេរេសា ដែលជាស្ថាបនិកក្រុមគ្រួសារនេះ។**

# ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់


Photo: L. Sovanna

លោកអភិបាលកាត់ខ្សែបូសម្ពោធអគារ "ផ្ទះនៃក្តីសង្ឃឹម"

អគារចំនួន ២ខ្នង ២ជាន់ ដែលបំពាក់បរិក្ខារគ្រប់គ្រាន់បានបើកសម្ពោធ ដើម្បីទទួលស្វាគមន៍ អ្នកផ្ទុកមេរោគ និងអ្នកជំងឺអេដស៍កាលពីថ្ងៃ៣០ វិច្ឆិកា ឆ្នាំ២០០៦កន្លងទៅ ក្រោមអធិបតីភាពលោកអភិបាលភូមិភាគភ្នំពេញ អេមីល ដេតម្បលោកជំទាវអ៊ុក ប៊ុនណា រដ្ឋលេខាធិការក្រសួងសុខាភិបាល បងប្រុសប្រធានក្រុមគ្រួសារមេត្តាករុណា និងបងប្អូនភ្ញៀវជាតិអន្តរជាតិយ៉ាងច្រើនកុះករ។ អគារថ្មីដែលទើបសម្ពោធនេះមានឈ្មោះ: "ផ្ទះនៃក្តីសង្ឃឹម" ស្ថិតនៅក្នុងភូមិត្រពាំងសាលា សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ។

បងប្រុសយ៉ុប ជាប្រធានក្រុមគ្រួសារនេះមានប្រសាសន៍ក្នុងពិធីថា: "ផ្ទះនៃក្តីសង្ឃឹម" បានសាងឡើងក្នុងគោលបំណងទទួលស្វាគមន៍ ចំពោះអស់អ្នកដែលអស់សង្ឃឹម ជាពិសេសគឺបងប្អូនដែលមានជំងឺ។ គាត់ផ្តល់សេចក្តីសង្ឃឹម មានសារៈសំខាន់ណាស់ សម្រាប់អ្នកជំងឺ។ បងប្រុសប្រធានបន្តទៀតថា នៅក្នុងផ្ទះនេះ អ្នកជំងឺនឹងទទួលបានការគាំពារ ថែរក្សាដោយផ្ទាល់ពីក្រុមបងប្រុស ព្រមទាំងទទួលថ្នាំពេទ្យនិងម្ហូបអាហារដែរ។ ប៉ុន្តែអ្វីដែលសំខាន់ គឺផ្តល់នូវសេចក្តីស្រលាញ់ដល់គេគ្រប់រូបដូចពាក្យស្លោក នៃក្រុមគ្រួសារ បាននិយាយថា: "ព្រះជាម្ចាស់គឺជាសេចក្តីស្រលាញ់"។ នៅក្នុងឱកាសនោះដែរ បងប្រុសសេបាស្ទាន ជាប្រធានក្រុមបងប្រុស នៅកម្ពុជា បានថ្លែងអំណរគុណដល់សប្បុរសជនទាំងអស់ ដែលជួយគាំទ្រ ទាំងកម្លាំងកាយ ចិត្ត សំភារៈ និងថវិកាជាដើម។ បងប្រុសបានថ្លែងអំណរគុណរដ្ឋាភិបាលកម្ពុជាដែលបានបង្កលក្ខណៈងាយស្រួល ដល់ដំណើរការកិច្ចការមនុស្សធម៌ ទាំងនេះ។ ចំពោះបេសកកម្មនៃក្រុមបងប្រុសមេត្តាករុណា បងប្រុសប្រធានបានសង្កត់ធ្ងន់ថា: "យើងមកទីនេះដើម្បីពាំនាំសេចក្តីស្រលាញ់អំពីព្រះជាម្ចាស់ដល់ប្រជាជន" សូមអរព្រះគុណព្រះជាម្ចាស់ ដែលផ្តល់ឱកាស ឱ្យក្រុមលោកស្រលាញ់ និងបំរើអ្នកក្រីក្រក្នុងនាមព្រះអង្គ។ បងប្រុសរំលឹកដល់អ្នកម្តាយតេរេសា ដែលតែងតែរំលឹកដល់បងប្រុស បងស្រី ទាំងអស់នូវព្រះបន្ទូលរបស់ព្រះយេស៊ូ: "ពេលខ្ញុំឃ្លាន អ្នករាល់គ្នាឱ្យអាហារខ្ញុំបរិភោគ។ ពេលខ្ញុំស្រេក អ្នករាល់គ្នាយកទឹកមកឱ្យខ្ញុំពិសា។ ពេលខ្ញុំជាប់ឃុំឃាំង អ្នករាល់គ្នាមកសួរសុខទុក្ខខ្ញុំ។ ពេលខ្ញុំមានជំងឺ អ្នករាល់គ្នាថែរក្សាខ្ញុំ។ គឺគ្រប់ពេលដែលអ្នករាល់គ្នាបានប្រព្រឹត្តអំពើអ្វីចំពោះអ្នកតូចតាចនោះ ក៏ដូចជាបានប្រព្រឹត្តចំពោះខ្ញុំដែរ"។

នៅក្នុងឱកាសដ៏ប្រសើរនេះ លោកជំទាវអ៊ុន ប៊ុនណា ដែលក្នុងនាមរាជរដ្ឋាភិបាល ក៏បានសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះរាល់សកម្មភាពរបស់ក្រុមបងប្រុស ដែលបានយកចិត្តទុកដាក់ចំពោះអ្នកដែលមានផ្ទុកមេរោគនិងអ្នកជំងឺអេដស៍ នៅប្រទេសកម្ពុជា ដែលសព្វថ្ងៃនេះ រាជរដ្ឋាភិបាលបានកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក្នុងការប្រយុទ្ធប្រឆាំង ទប់ស្កាត់ និងការរីករាលដាល នៃមេរោគអេដស៍។ លោកជំទាវ ក៏បានសង្កត់ធ្ងន់ថា អ្នកផ្ទុកមេរោគ និងអ្នកជំងឺអេដស៍គួរតែត្រូវបានទទួលការយកចិត្តទុកដាក់ និងគាំពារដោយគ្មានការរើសអើង។ រាជរដ្ឋាភិបាលរីករាយជានិច្ច ក្នុងការសហប្រតិបត្តិការជាមួយនិងដៃគូនានា ដើម្បីធ្វើការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងជំងឺដ៏កាចសាហាវនេះ។

សូមធ្វើការគូសបញ្ជាក់ផងដែរថា "ផ្ទះនៃក្តីសង្ឃឹម" នេះ គឺមានទទួលតែអ្នកជំងឺជាបុរសប៉ុណ្ណោះ ដោយធ្វើការរំលែកពីកន្លែងបងស្រីមេត្តាករុណានៅចោមចៅ។

លី សុវណ្ណា

## ប្រវត្តិរបស់ក្រុម

ក្រុមគ្រួសារមេត្តាករុណាបានបង្កើតឡើងដោយអ្នកម្តាយតេរេសា នៃក្រុងកាល់គុថា ប្រទេសឥណ្ឌា ឆ្នាំ១៩៥០។ ដំបូងមានតែក្រុមបងស្រីមេត្តាករុណាប៉ុណ្ណោះ។ ឆ្នាំ១៩៦៣ បងប្រុសអែនឌ្រូ បូជាចារ្យសហជីវិនព្រះយេស៊ូបង្កើតក្រុមបងប្រុសមេត្តាករុណារួមជាមួយអ្នកម្តាយតេរេសា។ បងប្រុសមេត្តាករុណាធ្លាប់មានវត្តមាននៅកម្ពុជា លើកទី១ ឆ្នាំ១៩៧៣។ ដោយសារសង្គ្រាមក្រុមបងប្រុសចាកចេញពីកម្ពុជាដោយបង្ខំ។ បងប្រុសម្នាក់ត្រូវគេសម្លាប់នៅពេលដែលខ្មែរក្រហមចូលភ្នំពេញឆ្នាំ១៩៧៥។ ក្រុមបងប្រុសមានវត្តមានលើកទី២ នៅឆ្នាំ២០០៣។

# សូមផ្ញើជីវិតលើព្រះជាម្ចាស់ហើយ!

**ការក្លាយខ្លួនទៅជាគ្រីស្តបរិស័ទមួយរូប មិនមែនជាការងាយស្រួលនោះទេ អ្នកនោះត្រូវប្រតិបត្តិតាមព្រះបន្ទូលព្រះជាម្ចាស់ គោរពស្រលាញ់អ្នកជុំវិញខ្លួន មិនត្រឹមតែប៉ុណ្ណោះ យើងក៏មិនត្រូវធ្វេសប្រហែសនឹងការដើរតាមរបស់ទម្លើព្រះអង្គផងដែរ។**


Photo: H. Sokhteary

លោកបូជាចារ្យ អ៊ុន ស៊ុន ឆ្លើយសំនួរទាក់ទងព្រះសហគមន៍

**សំណួរ :** តើធ្វើជាគ្រីស្តបរិស័ទមានន័យដូចម្តេច និងគួរប្រតិបត្តិខ្លួនយ៉ាងណា ?

**លោកបូជាចារ្យ អ៊ុន ស៊ុន :** ពាក្យថា គ្រីស្តបរិស័ទមានន័យថាគ្រីស្តជាស្តេចដែលប្រទាននូវការសង្គ្រោះ។ នៅពេលដែលយើងស្គាល់ព្រះគ្រីស្ត ជាព្រះសង្គ្រោះ ក្រោយមកយើងទទួលជាសិស្ស ជាអ្នកជឿដែលដើរតាមព្រះអង្គដោយយើងទទួលបុណ្យកំណើតថ្មី គឺការធ្វើពិធីបុណ្យជ្រមុជទឹកដែលនាំឱ្យយើងរួមស្លាប់រស់ជាមួយព្រះអង្គ។ ដូច្នេះគ្រីស្តបរិស័ទ វាមានន័យថា ជាអ្នកព្រមរួមស្លាប់រស់ជាមួយព្រះយេស៊ូ និងនៅពេលដែលយើងជាគ្រីស្តបរិស័ទ យើងត្រូវរស់នៅរបៀបណា? ការរស់នៅរបស់យើងត្រូវមានទំនាក់ទំនង យ៉ាងជិតស្និទ្ធជាមួយព្រះអង្គ យើងផ្ញើជីវិតលើព្រះអង្គរាល់ថ្ងៃ ព្រោះគ្រីស្តបរិស័ទជឿថា មានព្រះជាម្ចាស់តែមួយដែលប្រទាននូវជីវិតមកឱ្យមនុស្ស គឺជាម្ចាស់លើសត្វលោកទាំងអស់នៃការកកើតពិភពលោក។ ដូច្នេះយើងជាគ្រីស្តបរិស័ទ យើងគឺត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់។

**សំណួរ :** មានអ្នកខ្លះយល់ថា នៅពេលក្លាយខ្លួនជាគ្រីស្តបរិស័ទហើយ ពួកគេមានការងាយស្រួលក្នុងការរស់នៅ ព្រោះយើងផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់លែងមានកង្វល់អ្វីផ្សេងៗ តើនេះជាជំនឿរបស់មនុស្សម្នាក់ៗ ឬក៏ជាទូទៅតែម្តង ?

**លោកបូជាចារ្យ អ៊ុន ស៊ុន :** ពេលយល់ថា គ្រីស្តបរិស័ទមានការរស់នៅស្រួល និងមិនខ្លាចបាបនោះ តាមពិតគឺមិនដូចនេះទេ។ ខ្ញុំក៏សូមបញ្ជាក់ឱ្យច្បាស់ថា ការដែលយើងផ្តាច់នូវទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងមិនស្គាល់ព្រះជាម្ចាស់នៃជីវិត ត្រង់នេះហើយ! ដែលជាបាបធ្ងន់ក្នុងគ្រីស្តសាសនា ហើយនៅពេល ដែលមនុស្សផ្តាច់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ គឺមនុស្សរស់នៅឆ្ងាយពីព្រះអង្គ។

**សំណួរ :** យើងផ្តាច់ទំនាក់ទំនងនឹងព្រះជាម្ចាស់ យើងមានបាបធ្ងន់ តែបើយើងមានបញ្ហាជាមួយបងប្អូនយើង តើនេះជាបាបធ្ងន់ដែរឬយ៉ាងណា ?

**លោកបូជាចារ្យ អ៊ុន ស៊ុន :** ព្រះយេស៊ូតែងតែឱ្យយើងស្រលាញ់ព្រះអង្គដូចជាព្រះអង្គស្រលាញ់យើង មានន័យថា យើងត្រូវស្រឡាញ់អ្នកដទៃដូចព្រះអង្គស្រឡាញ់យើង។ សេចក្តីមួយដែលខ្ញុំចង់បញ្ជាក់អំពីទំនាក់ទំនងជាមួយព្រះជាម្ចាស់ គឺជីវិតមនុស្សជួបប្រទះនូវបញ្ហាផ្សេងៗ និងឧបសគ្គ។ ដូច្នេះបញ្ហាផ្សេងៗ និងឧបសគ្គគឺជាចំនុចមួយសំខាន់ណាស់ក្នុងជីវិតមនុស្សគ្រប់ៗរូប ដែលជាហេតុធ្វើឱ្យយើងត្រូវស្វែងរកព្រះ។ នៅពេលដែលយើងស្វែងរកព្រះ យើងត្រូវធ្វើការពិចារណាដែរថា តើព្រះណាដែលធ្វើឱ្យខ្ញុំមានជីវិតរស់ ដូច្នេះយើងត្រូវមានបទពិសោធន៍ក្នុងជីវិត។ ពេលណាដែលយើងទទួលការយល់ដឹងផ្សេងៗ យើងត្រូវយកមកពិចារណា ត្រូវគិតថា ជីវិតរបស់ខ្ញុំ សេចក្តីស្លាប់មានន័យយ៉ាងម៉េច? ពីមុនខ្ញុំខ្លាចស្លាប់ ប៉ុន្តែពេលដែលខ្ញុំបានស្គាល់ព្រះជាម្ចាស់ និងបានស្គាល់ព្រះបន្ទូលសន្យារបស់ព្រះយេស៊ូ អ្នកដែលរស់នៅ ជាមួយខ្ញុំអ្នកដែលជឿ និងអ្នកដែលផ្ញើជីវិតនឹងទទួលបានជីវិតថ្មីឡើងវិញ។ ដូច្នេះសេចក្តីនេះធ្វើឱ្យខ្ញុំមិនខ្លាចស្លាប់ ព្រោះខ្ញុំនឹងទទួលបានជីវិតថ្មីជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខ។

មុំ គន្ធា

## ស្រាយចម្ងល់

ប្រសិនបើប្រិយមិត្តអ្នកអាន អ្នកនាំសារ មានចម្ងល់ ឬមានសំណួរទាក់ទងទៅនឹងព្រះសហគមន៍កាតូលិក ក៏ដូចជារឿងរ៉ាវ ដែលប្រិយមិត្តមិនទាន់យល់ច្បាស់អំពីព្រះជាម្ចាស់។ ប្រិយមិត្តអាចសរសេរជាសំណួរមកការិយាល័យអ្នកនាំសារ តាមរយៈលោកបូជាចារ្យនៅជិតបំផុត ឬទូរស័ព្ទលេខ : ០១៦ ៣២៦ ៧៣៧ /០១២ ៣៣៨ ៩៨៥។ យើងខ្ញុំនឹងបកស្រាយជូនប្រិយមិត្តតាមរយៈការអញ្ជើញលោកបូជាចារ្យនានានៃភូមិភាគទាំងបី។





# ដូងជាដំណាំពហុប្រយោជន៍

**ដូងជាដំណាំដែលល្បីល្បាញជាងគេប្រចាំនៅតំបន់ត្រូពិច។ ផលិតផលពីផ្លែរបស់វាមានតម្លៃសម្រាប់ធ្វើជាអាហារ ធ្វើជានំ ឬរៀបចំម្ហូបផ្សេងៗ។ សាច់ដូងយកចម្រាញ់ធ្វើជាប្រេង ដែលហៅថា ប្រេងដូង។ ទឹកដូងយកធ្វើជាភេសជ្ជៈ។ ផ្កាធ្វើស្ករ ស្រា និងទឹកខ្មេះ ហើយឫសធ្វើជាឱសថ-ល-។**


Photos: P. Samphy

ផ្លែដូង

### លក្ខណៈបរិស្ថាន

សីតុណ្ហភាពមធ្យមសម្រាប់ការដុះលូតលាស់ដំណាំដូង គឺនៅចន្លោះ២៥-៣០អង្សារ ហើយកម្រិតដែលទាបបំផុត គឺ២០អង្សារ។ បរិមាណទឹកភ្លៀងដែលល្អប្រសើរសម្រាប់ដូងផ្តល់ទិន្នផលខ្ពស់គឺ១៣០០-២៣០០មម ក្នុងមួយឆ្នាំ។ ដំណាំដូងអាចដុះលូតលាស់បាននៅតំបន់ដែលបរិមាណទឹកភ្លៀងមានតែពី២០០-៣០០មម ក្នុងមួយឆ្នាំបានដែរ បើគេដាំនៅជិតប្រភពទឹកដែលមានសំណើមជាប់ជាប្រចាំរៀងរាល់ឆ្នាំ។ វាគឺជាដំណាំដែលត្រូវការពន្លឺក្នុងការដាំដុះ ដូច្នេះគេត្រូវជៀសវាងដាំនៅកន្លែងណា ដែលគ្មានពន្លឺព្រះអាទិត្យចាំងចូលល្អ។ ដូងអាចលូតលាស់លើប្រភេទដីផ្សេងៗគ្នា ជាពិសេសដីដែលមានស្រទាប់ដីជាតិជ្រៅមានខ្យល់ចេញចូលល្អនិងច្រោះទឹកជាប្រភេទដីគ្រាប់ធំ។ ចំពោះដីខ្សាច់ ដំណាំដូងក៏អាចដុះបានធម្មតា កាលណាគេដាំជិតប្រភពទឹក។ ដំណាំដូងនឹងផ្តល់ទិន្នផលល្អនៅលើដីដែលមានជាតិអំបិល និងសើមជានិច្ច។

## កន្លែងសិក្សា

ប្រសិនបើលោកអ្នកចង់សិក្សាអំពីរបៀប ឬបច្ចេកទេសនៃការដាំដំណាំគ្រប់ប្រភេទគឺមាននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) ឬអាចអញ្ជើញបុគ្គលិករបស់សេដាកទៅបង្រៀនដល់ទីកន្លែងតែម្តងដោយពិភាក្សាតម្លៃសមរម្យ។ ទំនាក់ទំនងទូរស័ព្ទ : ០១២ ៣២៩៧១០។


Photos: P. Samphy

ដូងជាដំណាំផ្តល់ប្រយោជន៍ច្រើនដែលប្រជាជននៅតំបន់ត្រូពិចចូលចិត្តដាំដុះ

### បច្ចេកទេសដាំដុះ

គេអាចចែកពូជដូងជា២ប្រភេទ គឺដូងខ្ពស់ និងដូងតឿ។ គេជ្រើសរើសផ្លែដូងធ្វើពូជ យកពីដើមដែលមានផ្លែច្រើនជាប់រហូត និងយកផ្លែដែលធំជាងគេមានសាច់ក្រាស់ និងទុំល្អ។ មុននឹងដាំ គេត្រូវបណ្តុះវា ជាការល្អ គេត្រូវយកផ្លែដូងទៅទុកក្នុងកន្លែងម្លប់ កុំឱ្យត្រូវភ្លៀង និងឱ្យមានខ្យល់ចេញចូលចំនួនពី ៣អាទិត្យទៅមួយខែ ដើម្បីឱ្យផ្លែទាំងនោះកាន់តែទុំល្អ។ គេត្រូវស្រោចទឹករាល់ថ្ងៃ (កាលណាគ្មានភ្លៀង) ផ្លែដូងចាប់ផ្តើមដុះពន្លកចាប់ពី៨-១២អាទិត្យ ក្រោយបណ្តុះ។ កូនដូងដែលត្រូវដកយកទៅដាំ គឺនៅពេលវាមានធាងស្លឹក ២-៤។ ពេលវេលាល្អដែលត្រូវដាំគឺនៅដើមរដូវភ្លៀង។ គេមិនត្រូវកប់កូនដូងឱ្យជ្រៅលើសករបស់វាទេ យើងត្រូវលុបដីពីលើផ្លែនេះត្រឹមកម្ពស់ ៥ស.មប៉ុណ្ណោះ ហើយយកចំបើងមកគ្របក្បែរគល់ កុំឱ្យសំណើមហួតអស់។ បើសិនមានសត្វកណ្តុរ យើងត្រូវហ៊ុមព័ទ្ធកូនដូងដោយសំណាញ់លួស ឬរបងរនាបឫស្សី។ ការថែទាំជម្រះសំអាតគល់ដូងគឺត្រូវធ្វើឱ្យបានញឹកញាប់ក្នុង ៥ឆ្នាំដំបូង។ បន្ទាប់មកគេអាចធ្វើត្រឹម ២ដងក្នុងមួយឆ្នាំ។ ដើម្បីរក្សាដីឱ្យមានគុណភាពល្អ គេត្រូវប្រើជីសរីរាង្គលាយជីគីមី។ គេក៏អាចដាក់អាចម៍គោដែលសុះល្អពី ៥០គ.ក្រ ទៅ ១០០គ.ក្រ ក្នុងមួយដើម ក្នុងមួយឆ្នាំ។

### ជំងឺ

មានជំងឺប្រេះដើម។ ជំងឺនេះកើតឡើងពេលដើមមានអាយុពី១៨-២២ឆ្នាំ។ ដំបូងផ្នែកនៃដើមដូងប្រេះពីលើមកក្រោមហូរជ័រ ហើយប្រែពណ៌បន្តិចម្តងៗទៅជាពណ៌ត្នោតក្រម៉ៅ។ ពេលនោះផ្នែកខាងក្នុងនៃដើមរលួយ។ ដើមដូងនឹងងាប់ក្នុងរយៈពេល៤ ឬ៥ឆ្នាំក្រោយមក។ ដើម្បីការពារដើមដូងទើបនឹងកើតមានជំងឺនេះ គេត្រូវដុតនៅត្រង់កន្លែងដែលប្រេះរួចហើយយកដីឥដ្ឋលាយអំបិលទៅបិទនៅកន្លែងប្រេះនោះ។

ផាត សំភី

## រូបទាំងពីរខាងក្រោមនេះ មានចំនុចខុសគ្នា ៧។ សូមប្រិយមិត្តសាកល្បងរកទៅមើល តើចំនុចទាំងនោះនៅទីណាខ្លះ?






# ដាក់ទូទូរស័ព្ទ

**ការទំនាក់ទំនងគ្នាតាមរយៈទូរស័ព្ទកំពុងមានការពេញនិយមយ៉ាងខ្លាំងនាពេលបច្ចុប្បន្ននេះ។ ដូច្នេះហើយទើបគេឃើញមុខរបរដាក់សេវាកម្មទូរស័ព្ទតាមទីសាធារណៈមានការរីកដុះដាលព្រោងព្រាត។**




Photo: P. Samphy

គាត់កំពុងពិនិត្យមើលនាទីយកលុយក្រោយពីភ្ញៀវបានទូរស័ព្ទរួច

ដើម្បីផ្តល់សេវាកម្មនេះបាន យើងត្រូវមានកន្លែងសមរម្យគឺមានមនុស្សចេញចូលច្រើន។ យើងគួរមានទូរស័ព្ទ២ ឬក៏៣ គ្រឿងផ្លាស់ប្តូរគ្នា ធុងទូរស័ព្ទ សម្ភារៈផ្សេងៗ ចុងក្រោយ គឺការភ្ជាប់ប្រព័ន្ធ និងការទិញកាតបញ្ចូលទឹកប្រាក់។ យើងគួរចំណាយដើមទុនយ៉ាងតិចក៏៣០០ដុល្លារដែរ។ ប៉ុន្តែបើយើងមាន៥០០ដុល្លារ យើងអាចទិញកាតមកលក់ថែមទៀត។

ស្រុកខ្មែរ មានក្រុមហ៊ុនបណ្តាញទូរស័ព្ទជាច្រើន ដូចជាក្រុមហ៊ុន MobiTel (០១២) Camshin (០១១) និង Samart (០១៥-០១៦)ជាដើម។ តែអ្នកដាក់ទូរស័ព្ទគេច្រើននិយមភ្ជាប់ប្រព័ន្ធ០១២ និង០១១ ពីព្រោះវាមានការងាយស្រួលច្រើន។ នេះបើតាមសំដីរបស់លោកគឹម ហែនសួរ្យដែនដែលប្រកបរបរដាក់ទូទូរស័ព្ទ នៅមុខវិទ្យាល័យចាក់ទុក រាជធានីភ្នំពេញ។ លោកក៏បន្តថា យើងទៅក្រុមហ៊ុន រួចប្រាប់គេថាយើងចង់រកស៊ី គេនឹងភ្ជាប់ប្រព័ន្ធឱ្យ យើងតាមគោលការណ៍ដែលគេមានស្រាប់។ តួយ៉ាងបច្ចុប្បន្នក្រុមហ៊ុន០១១ ប្រព័ន្ធរកស៊ី គឺគេកាត់យើងមួយថ្ងៃ ៨០សេន និងហៅចេញមួយនាទី ៣សេន។ ចំណែកក្រុមហ៊ុន០១២ គេកាត់យើងមួយថ្ងៃ ៨៥សេន និងហៅចេញមួយនាទី ៤សេន ប៉ុន្តែការហៅចេញក្នុងមួយខែ គឺមិនត្រូវឱ្យលើសពី ៣៥០០នាទីឡើយ បើសិនលើស គេយកយើង ៦សេន ក្នុងមួយនាទី។

លោកគឹម ហែនសួរ្យដែន និយាយថា សេវាកម្មដាក់ទូរស័ព្ទចល័តនេះ គឺជាមុខរបរមួយងាយស្រួល និងមិនសូវបញ្ចេញកម្លាំងច្រើន។ ក្នុងមួយថ្ងៃយើងអាចរកចំណូលបានយ៉ាងតិចក៏២០០០០រៀលដែរ។ ប៉ុន្តែ យើងត្រូវប្រុងប្រយ័ត្នលើចំនុចមួយចំនួន ដូចជា អតិថិជនខ្លះទូរស័ព្ទចេញទៅក្រៅប្រទេសដែលមានតម្លៃខុសពីតម្លៃក្នុងស្រុក។ យើងត្រូវយកចិត្តទុកដាក់ផ្ទៀងផ្ទាត់នាទី។ ម្យ៉ាងទៀត យើងគួរដាក់ទូរស័ព្ទសើរអន់ព្រោះអាចមានគេបន្លំលួច។ ដើម្បីទាក់ម៉ូយឱ្យបានច្រើន យើងត្រូវមានយុទ្ធវិធី បម្រើសេវាកម្មឱ្យបានដិតដល់ រហ័សរហួន មានចិត្តអត់ធ្មត់ បើខ្វះខាតតិចតួច យើងចោលឱ្យគេ។ លោកសួរ្យដែន អះអាងថា ពេលខ្លះ វាមានការរីករាយដែរនៅពេលមានអតិថិជនចូលទូរស័ព្ទច្រើន ដោយសារវាមាន-តម្លៃថោក គឺមួយនាទី ៣០០រៀលប៉ុណ្ណោះ។

ផាត សំភី

### ក្រុមហ៊ុនទូរស័ព្ទ

MobiTel (012) ឋិតនៅអគារលេខ៣៣ ផ្លូវព្រះសីហនុ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : ០១២ ៨០០ ៨០០។ ក្រុមហ៊ុន Camshin (011) ស្ថិតនៅអគារ៦៦ ផ្លូវម៉ៅសេទុង រាជធានីភ្នំពេញ ទូរស័ព្ទ : ០២៣ ៣៦៧ ៨០១-៥។ ក្រុមហ៊ុន Cambodia Samart (016) ស្ថិតនៅផ្លូវនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញដែរ។



# ជំងឺពុកធ្មេញ

**ធ្មេញជាសោភ័ណភាពលើកសម្រស់មនុស្សគ្រប់វ័យឱ្យកាន់តែមានភាពទាក់ទាញបណ្តាអ្នករស់នៅជុំវិញខ្លួន និងជួយដល់ការរំលាយអាហារផងដែរ។ ដូច្នេះ តើត្រូវថែទាំយ៉ាងណាដើម្បីឱ្យធ្មេញល្អស្អាត ?**

បើយោងតាមប្រសាសន៍លោកទន្តបណ្ឌិតឃុត មី ជាប្រធានគ្លីនិកធ្មេញអន្តរជាតិ និងជាប្រធានគណៈទន្តពេទ្យ រាជធានីភ្នំពេញ បានឱ្យដឹងពីបញ្ហាដែលកើតមានឡើងចំពោះ ធ្មេញថា : "ជម្ងឺធ្មេញមានច្រើនប្រភេទ ដូចជាការរលាកអញ្ចាញធ្មេញ និងការពុកធ្មេញ-ល-"។ លោកបានលើកយកជំងឺពុកធ្មេញមកធ្វើការពន្យល់ថា ជំងឺពុកធ្មេញ វាកើតឡើងដោយសារការញ៉ាំស្ករ បង្អែម ឬអាហារ ដែលមានជាតិផ្អែមច្រើន ហើយយើងពុំបានដុះធ្មេញ ដែលបណ្តាលឱ្យមានកើតជំងឺពុកធ្មេញ។ ការកើតជំងឺពុកធ្មេញនេះ វាអាចបណ្តាលឱ្យកើតនូវជំងឺផ្សេងៗទៀតដែរ ដូចជាកាលណាយើងមានជំងឺពុកធ្មេញ វាធ្វើឱ្យយើងឈឺរហូតដល់ចាក់ធ្មេញអស់ ខានញ៉ាំអាហារ។ មួយទៀត វាទាក់ទងទៅដល់បេះដូងព្រោះនៅក្នុងធ្មេញពុករបស់យើង មានបាក់តេរីជាច្រើន ហើយនៅពេលដែលធ្មេញពុកខ្លាំងធ្វើឱ្យប៉ះពាល់នឹងសរសៃ ពេលនោះ មេរោគជ្រៀតចូលតាមឈាម អាចចូលទៅក្នុងបេះដូង ដែលវាធ្វើឱ្យអាចប៉ះពាល់ទៅដល់បេះដូងទៀតផង។

ដើម្បីការពារធ្មេញកុំឱ្យឆាប់ខូច មនុស្សគ្រប់គ្នាត្រូវដុះធ្មេញឱ្យបានយ៉ាងហោចណាស់ ២ដង ក្នុង១ថ្ងៃ (ព្រឹក និងល្ងាច) ទៀងទាត់ទៅជួបជាមួយគ្រូពេទ្យធ្មេញ ៦ខែ ឬមួយឆ្នាំម្តង ទោះបីជាមិនឈឺក៏ដោយ គឺត្រូវតែមកពេទ្យដើម្បីពិនិត្យ។ ការប្រើអំបិលក៏ជួយអញ្ចាញធ្មេញម្យ៉ាងដែរ តែបើយើងមិនប្រើច្រាស់ទេ វាក៏នៅតែបណ្តាលឱ្យមានជំងឺពុកធ្មេញដដែល ដោយសារយើងមិនបានដុះវាឱ្យបានសព្វទីកន្លែង។ ដូចនេះ យើងក៏ត្រូវការទៅជួបគ្រូពេទ្យ និងគោរពតាមបណ្តាំរបស់ពេទ្យជាប្រចាំនោះ ធ្មេញរបស់យើងនឹងមានសោភ័ណភាពល្អ ព្រមទាំងធ្វើឱ្យយើងមានសុខភាពល្អផងដែរ។

ការពុកធ្មេញ មានផលប៉ះពាល់ខ្លាំងចំពោះស្ត្រីដែលមានផ្ទៃពោះក្នុងរយៈពេលដែលមានគភ៌ផងដែរ។

មុំ គន្ធា



Photo: M. Kunthear

លោកទន្តបណ្ឌិតឃុត មី ប្រធានគ្លីនិកធ្មេញអន្តរជាតិ

### កន្លែងព្យាបាល

បើលោកអ្នកមានបញ្ហាមាត់ធ្មេញ អាចទៅព្យាបាលនៅគ្លីនិកធ្មេញអន្តរជាតិនៅផ្ទះ ១៩៣ ផ្លូវ ២០៨ ទល់មុខឈាងបណ្ណាគារ PBC ឬទូរស័ព្ទលេខ : ០១៦ ៥៥ ៣៣ ៦៦។

# បងស្រី ជេត: "ខ្ញុំចូលចិត្តលើកទឹកចិត្តស្ត្រីដែលមានបញ្ហាក្នុងជីវិត"



បងស្រីជេត

Photo: H. Soktheary

**បងស្រីជេតគឺជាកូនទី២ក្នុងចំណោមបងប្អូន៣នាក់ដែលសុទ្ធតែស្រីនៅក្នុងគ្រួសារ។ បងស្រីរស់នៅក្នុងជីវិតជាមួយបងស្រីតាំងពីខ្លួនគាត់នៅជាកុមារភាពមកម្ល៉េះ។**

"នៅពេលដែលខ្ញុំសម្រេចចិត្តចូលរួម ក្នុងគ្រួសារនោះ ឪពុកម្តាយរបស់ខ្ញុំមានការពិបាកចិត្ត មិនតែប៉ុណ្ណោះ ខ្ញុំបានអធិដ្ឋានយ៉ាងខ្លាំងដើម្បីសុំព្រះជាម្ចាស់ឱ្យខ្ញុំមានសេចក្តីក្លាហានក្នុងការនិយាយជាមួយពួកគាត់"។ នេះជាសំដីបងស្រីជេត ប្រធានក្រុមគ្រួសារសាឡេស្យាននៅទួលគោក។

ក្នុងទឹកមុខញញឹម បងស្រីក៏បន្តថា គាត់មានការសប្បាយចិត្តយ៉ាងខ្លាំងដោយបានមកធ្វើការផ្ទាល់ជាមួយយុវនារីក្រីក្រ។ គាត់ឃើញសេចក្តីសង្ឃឹមដ៏ជ្រាលជ្រៅដែលកើតមានក្នុងជីវិតរបស់យុវនារីនៅទីនេះ។ នៅក្នុងបេសកកម្មរបស់ក្រុមបងស្រីគឺក្រុមមានទស្សនៈថា ការអភិវឌ្ឍន៍ដោយសន្តិភាពនៅក្នុងប្រទេសកម្ពុជា ដែលយុវជន យុវនារីទទួលបានការបណ្តុះបណ្តាលនូវជំនាញដែលមានគុណភាពពិតប្រាកដ ហើយមានតម្លៃនៃសីលធម៌កើតមាន។ បងស្រីនិយាយ ដោយលើកក្រដាសបង្ហាញ និងក្នុងសម្លេងស្រទន់ថា: "ខ្ញុំក៏ចង់ឃើញស្ត្រីនៅទីនេះ គឺមានការប្រឡូកជាមួយនិងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងសង្គម"។ ក្រុមគ្រួសាររបស់បងស្រីមានគោលដៅសំខាន់ គឺប្រកាសនូវសេចក្តីសង្ឃឹមដល់យុវជនយុវនារី។ ចំពោះគោលការណ៍ដែលសំខាន់របស់ក្រុមបងស្រី គឺធ្វើការជាមួយយុវនារី ហើយគោលការណ៍យើងចំពោះព្រះសហគមន៍ធ្វើឡើងដើម្បីអភិវឌ្ឍ យុវជន យុវនារីនៅក្នុងសង្គមតាមរយៈខ្លួនរបស់គេផ្ទាល់និងក្រុមគ្រួសាររបស់គេ ដែលនេះជាព្រះអំណោយទាននៃព្រះជាម្ចាស់។ ក្រុមគ្រួសារមាននូវព្រះអំណោយទានជាពិសេសទៅលើការអប់រំ ទាំងប្រាជ្ញាស្មារតី ទាំងផ្លូវកាយ ហើយនិងផ្លូវចិត្ត។

បងស្រីបន្តទៀតថា: "យើងជឿថា ការអប់រំមិនគ្រាន់តែនៅក្នុងថ្នាក់នោះទេ ប៉ុន្តែមានសកម្មភាពសម្រាប់សិស្ស គឺដូចជាហាត់រៀង សម្រាប់បុណ្យណូអែលព្រមជាមួយសកម្មភាពជាច្រើនទៀត"។ បងស្រីបន្តថា ក្នុងនាមជាបេសកជនម្នាក់ យើងពុំអាចទុកនូវ សេចក្តីស្រឡាញ់ក្នុងខ្លួនបានទេ។ បើសិនយើងស្រឡាញ់នរណាម្នាក់ហើយ យើងអាចលះបង់គ្រប់យ៉ាងសម្រាប់គេ។

បងស្រីជនជាតិហ្វីលីពីននេះក៏បានបន្តថា ពេលខ្លះគាត់មានការលំបាកចំពោះការដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងជីវិតគ្រួសារនិងបញ្ហាផ្លូវចិត្តរបស់សិស្សដែរ។ តែគាត់សង្កេតឃើញថា យុវជន យុវនារីទីនេះ មានលក្ខណៈល្អជាងក្មេងៗដែលនៅប្រទេសផ្សេងៗ។ ពួកគេមានការគោរពហើយស្តាប់បង្គាប់ និងបើកចំហចិត្តជាខ្លាំង។

សម្រាប់ថ្ងៃអនាគត ក្រុមបងស្រីរៀបចំផែនការដើម្បីជួយយុវនារីក្រីក្របន្ថែមទៀត។ ហើយបងស្រីគ្រប់រូបនឹងត្រូវបំប៉ននូវជំនាញថ្មីៗដូចជាផ្នែកចិត្តសាស្ត្រ និងផ្នែកព្រលឹងវិញ្ញាណដើម្បីជួយដល់នារីដែលមានបញ្ហាក្នុងជីវិតអាចរីកចម្រើនបាន។

ហ៊ូ សុខធារី

## ព្រឹត្តិការណ៍សំខាន់!

- ថ្ងៃទី១២-១៣ ធ្នូ: សិក្ខាសាលាគ្រូអប់រំជំនឿ ភូមិភាគកំពង់ចាម ដែលនឹងប្រព្រឹត្តទៅនៅព្រះសហគមន៍ព្រៃវែង។
- ថ្ងៃទី១៦ ធ្នូ: ព្រះសហគមន៍ផ្សារតូចភ្នំពេញ រៀបចំពិធីសម្រុះសម្រួលរួមនៅវេលាម៉ោង ៤រសៀល។
- ថ្ងៃទី២០ ធ្នូ: ព្រះសហគមន៍កំពតសួរសុខទុក្ខ និងចែកអាហារដល់អ្នកជាប់ពន្ធនាគារក្នុងខេត្តចំនួន ១៧០នាក់។
- ថ្ងៃទី២២-៣១ ធ្នូ: សិក្ខាសាលានៃគ្រូអប់រំជំនឿ នៅភូមិភាគកំពង់ចាមជាមួយនិងកម្មវិធីការ៉ូល និងសេដ្ឋា។
- ថ្ងៃទី២៤ ធ្នូ: អភិបូជាវេលាម៉ោង ៨ព្រឹក និងម៉ោង ៦ល្ងាច ដើម្បីអបអរព្រះកុមារយេស៊ូដែលយាងមក ធ្វើឡើងនៅព្រះសហគមន៍ផ្សារតូច។
- ថ្ងៃទី២៤ ធ្នូ: ព្រះសហគមន៍កំពតជួយដល់គ្រួសារក្រីក្រចំនួន ៥០គ្រួសារ ដែលនៅក្នុងនោះ មានមុង ព្រមទាំងសំភារៈអនាម័យជាច្រើនទៀត។
- ថ្ងៃទី២៥ ធ្នូ: ពិធីបុណ្យណូអែលសម្រាប់ក្មេងៗ ៧០០នាក់ នៅចំការទៀង។
- ថ្ងៃទី២៥ ធ្នូ: ព្រះសហគមន៍ខេត្តកំពតមានរៀបចំពិធីបុណ្យណូអែលពេលល្ងាច និងមានសម្តែងរឿងព្រះយេស៊ូប្រសូតតាមរបៀបរឿងរាមកេរ្តិ៍ទៀតផង។
- ថ្ងៃទី២៥ ធ្នូ: បុណ្យព្រះយេស៊ូប្រសូត។
- ថ្ងៃទី៣១ ធ្នូ: មានរៀបចំការប្រជុំគណៈកម្មាការនៅព្រះសហគមន៍ផ្សារតូចទាំងអស់ដើម្បីវាយតម្លៃប្រចាំឆ្នាំ និងរិះគិតអំពីគោលដៅទៅឆ្នាំក្រោយផងដែរ។
- ជារៀងរាល់សប្តាហ៍: ព្រះសហគមន៍ផ្សារតូច អង្គាសថវិកាដើម្បីជួយដល់ជនក្រីក្រក្នុងឱកាសបុណ្យព្រះគ្រីស្តប្រសូត។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្ស៊ីរ៉ាល់ដូ